Cambodian Federation of Employers & Business Associations
សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា

# មាគ៌ាឆ្ពោះទៅកាន់ភាពរុងរឿង

## អាទិភាពនៃគោលនយោបាយដើម្បីបង្កើតបរិយាកាសអំណោយផលដើម្បី ការបង្កើត និងអភិវឌ្ឍសហគ្រាសឲ្យមានចីរភាពនៅព្រះរាជាណាចក្រកម្ពុជា

# ចក្ខុវិស័យពាណិជ្ជកម្មឆ្នាំ ២០២០

## CAMFEBA



# អំពី CAMFEBA

ចាប់តាំងពី សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា(CAMFEBA)បានបង្កើតឡើងនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០០ មក CAMFEBA ទទួលបាននូវការទទួលស្គាល់ពីសំណាក់រាជរដ្ឋាភិបាល អង្គការអន្តរជាតិខាងការងារ (ILO) និងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិដទៃទៀតថាជាសមាគមធំជាងគេបំផុត ដែលតំណាងឲ្យនិយោជកនៅក្នុងវិស័យជាច្រើន នៅកម្ពុជា ដូចជា វិស័យកាត់ដេរ ធនាគារ សណ្ឋាគារ ។ល។ CAMFEBA គឺជាអង្គការមេរបស់និយោជកនៅកម្ពុជា និងជាតំណាងតែមួយគត់របស់និយោជកទៅចូលរួមនៅក្នុងសន្និសីទអង្គការអន្តរជាតិខាងការងារ ដែលរៀបចំឡើងជារៀងរាល់ឆ្នាំ នៅទីក្រុងហ្សឺណែវ។ យើងជាសមាជិកនៃសហភាពនិយោជកអាស៊ាន (ACE) សហភាពនិយោជកអាស៊ីប៉ាស៊ីហ្វិក (CAPE) ក៏ដូចជាអង្គការនិយោជកអន្តរជាតិ (IOE)។

គិតមកដល់ខែមករា ឆ្នាំ២០១៤ CAMFEBA មានក្រុមហ៊ុនចំនួន ២១២ ជាសមាជិកធម្មតា និងសមាគមពាណិជ្ជកម្មចំនួន ៩ ជាសមាគមសមាជិក ព្រមទាំងអង្គការមិនរកប្រាក់ចំណេញចំនួន ២៤ ជាសមាជិកសហការី។ សរុបមក CAMFEBA តំណាងក្រុមហ៊ុនពាណិជ្ជកម្មជាង ២០០០ ទាំងមានសហជីព និងទាំងគ្មានសហជីព។

**បេសកកម្មរបស់យើងគឺ៖** "យើងជាសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្ម។ យើងលើកកម្ពស់បរិយាកាសដើម្បីភាពរីកចំរើន នៃពាណិជ្ជកម្ម និងជួយជ្រោមជ្រែងភាគីនិយោជកដើម្បីភាពជោគជ័យឥតខ្ចោះក្នុងការធ្វើពាណិជ្ជកម្មរបស់ខ្លួន"។
**ចក្ខុវិស័យរបស់យើងគឺ៖** "ពាណិជ្ជកម្មជោគជ័យ កម្ពុជារុងរឿង"។

**មូលហេតុក្លាយជាសមាជិករបស់យើង មានដូចតទៅ៖**

១. ការប្រឹក្សាយោបល់អំពីការអនុវត្តខាងផ្នែកធនធានមនុស្ស និងការងារ
២. ការផ្សព្វផ្សាយព័ត៌មាន
៣. ការបណ្តុះបណ្តាល និងអភិវឌ្ឍ
៤. ឱកាសបង្កើតបណ្តាញ
៥. សេវាកម្មបំពេញកាតព្វកិច្ចតាមច្បាប់
៦. ការបញ្ចុះបញ្ចូល និងការតស៊ូមតិ
៧. ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ

*ឯកសារនេះត្រូវបានបោះពុម្ពដោយមានជំនួយហិរញ្ញវត្ថុពី (ការិយាល័យសម្រាប់សកម្មភាពនិយោជក) អង្គការអន្តរជាតិខាងការងារ។*

*ការទទួលខុសត្រូវចំពោះមតិយោបល់ក្នុងរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធតែម្នាក់គត់។ អង្គការអន្តរជាតិខាងការងារ (ILO)ពុំទទួលខុសត្រូវចំពោះភាពត្រឹមត្រូវ អាចទទួលយកបាន ឬអាចជឿជាក់បាននៃឯកសារ ព័ត៌មាន ឬមតិយោបល់ណាមួយ នៅក្នុងរបាយការណ៍នេះទេ។*

International Labour Organization

# បេសកកម្មរបស់យើង

*"យើងជាសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្ម។ យើងលើកកម្ពស់បរិយាកាសដើម្បីភាពរីកចំរើន នៃពាណិជ្ជកម្ម និងជួយជ្រោមជ្រែងភាគីនិយោជកដើម្បីភាពជោគជ័យឥតខ្ចោះក្នុងការធ្វើពាណិជ្ជកម្មរបស់ខ្លួន"*

# ចក្ខុវិស័យរបស់យើង

*"ពាណិជ្ជកម្មជោគជ័យ កម្ពុជារុងរឿង"*

# តម្លៃរបស់យើង



# អារម្ភកថា

*ក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ កំណែទម្រង់សំខាន់ៗផ្នែកសេដ្ឋកិច្ចបានជួយប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចផ្តោតលើពាណិជ្ជកម្ម ដែលមានវិស័យសេវាកម្ម និងឧស្សាហកម្មកំពុងតែរីកលូតលាស់។ កត្តាប្រាក់ឈ្នួលមានលក្ខណៈប្រកួតប្រជែង លក្ខខណ្ឌការងារល្អ និងបរិដ្ឋានល្អ រួមផ្សំគ្នា បានជួយជំរុញពាណិជ្ជកម្មកម្ពុជា និងបានទាក់ទាញការវិនិយោគអន្តរជាតិ។ កម្ពុជាមានឱកាសដើម្បីមានភាពរុងរឿងបន្ថែមទៀត ដែលស្ថិតលើទំហំដីដ៏ធំលាតសន្ធឹង និងប្រជាជនវ័យក្មេងចំនួនច្រើន ក៏ដូចជាទីតាំងភូមិសាស្ត្រសំខាន់នៅក្នុងតំបន់ដែលរីកចម្រើនលឿនបំផុតមួយនៅលើពិភពលោក។*

*ទោះជាយ៉ាងណា ដើម្បីប្រែក្លាយឱកាសទាំងនេះឲ្យទៅជាពាណិជ្ជកម្ម ផលិតផល និងការងារ គោលនយោបាយថ្នាក់ជាតិរបស់យើងត្រូវតែគាំពារការអភិវឌ្ឍវិស័យឯកជន និងលើកទឹកចិត្តចំពោះការពង្រីកវិស័យសេដ្ឋកិច្ច។*

*តាមរយៈការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយ និងការពិភាក្សាល្អិតល្អន់ជាមួយនឹងក្រុមហ៊ុនជាសមាជិករបស់យើង ក្នុងរយៈពេល ១២ ខែកន្លងមកនេះ CAMFEBA បានកំណត់ឃើញគោលនយោបាយសំខាន់ៗចំនួនបួន ដែលយើងចាំបាច់ត្រូវតែផ្តោតកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ អាទិភាពទាំងបួនសម្រាប់ធ្វើសកម្មភាពនេះ មានដូចតទៅ៖*

*១. អាទិភាពទី ១៖ ផ្គូរផ្គងជំនាញទៅនឹងសេចក្តីត្រូវការរបស់សេដ្ឋកិច្ចរបស់យើងដែលកំពុងផ្លាស់ប្តូរ*

*២. អាទិភាពទី ២៖ ការធ្វើឲ្យប្រសើរឡើងនូវទំនាក់ទំនងនៅកន្លែងធ្វើការ*

*៣. អាទិភាពទី ៣៖ លើកកម្ពស់រចនាសម្ព័ន្ធអភិបាលកិច្ច*

*៤. អាទិភាពទី ៤៖ បង្កើតបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិដ៏ល្អប្រសើរ ដើម្បីផ្តល់លទ្ធភាពដល់ការរីកលូតលាស់ និងការអភិវឌ្ឍសហគ្រាស*

*អាទិភាពទាំងនេះពិតជាអាទិភាពលំបាក ប៉ុន្តែមិនមែនជាបញ្ហាប្រឈមដែលមិនអាចជម្នះបាននោះទេ ហើយយើងមានជំនឿជឿជាក់យ៉ាងមុតមាំថា ដោយភាគីពាក់ព័ន្ធទាំងអស់ធ្វើសកម្មភាពរួមគ្នា យើងអាចបង្កើតបាននូវបរិយាកាស ដើម្បីធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន និងធ្វើពិពិធកម្មសេដ្ឋកិច្ច បង្កើតការងារមានគុណភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗគ្នា។*

*ក្នុងឋានៈជាអង្គការមានភាពជាតំណាងបំផុតខាងផ្នែកពាណិជ្ជកម្មនៅកម្ពុជា យើងប្តេជ្ញាថា នឹងជួយកម្ពុជាឲ្យបន្តអភិវឌ្ឍក្លាយជាប្រទេសសេដ្ឋកិច្ចដែលអភិវឌ្ឍយ៉ាងសកម្ម និងពិពិធកម្ម បន្ថែមពីលើការផ្តល់សេវាកម្មជូនសមាជិករបស់យើង។ យើងទទួលស្គាល់ភាពចាំបាច់ក្នុងការចូលរួមចំណែកកំណត់រកបញ្ហា ព្រមទាំងរៀបចំ និងអនុវត្តនូវដំណោះស្រាយ។ របាយការណ៍នេះមានគោលបំណងបែបនោះ។*

ប្រធានក្រុមប្រឹក្សាភិបាល

វ៉ាន់ ស៊ូអៀង

# មាតិកា

អារម្ភកថា.....iii
មាតិកា..... iv
អក្សរកាត់.....v
សេចក្តីផ្តើម.....1
អាទិភាពទី ១៖ បង្កើតជំនាញដើម្បីប្រកួតប្រជែង៖ ការអប់រំ ការបណ្តុះបណ្តាល និងការសិក្សារៀនសូត្រមួយជីវិត.....3
យល់ដឹងអំពីបញ្ហា.....3
វឌ្ឍនភាពបច្ចុប្បន្ន.....5
អនុសាសន៍សម្រាប់គោលនយោបាយ.....7
អាទិភាពទី ២៖ ការធ្វើឲ្យទំនាក់ទំនងនៅកន្លែងធ្វើការកាន់តែល្អប្រសើរ៖ ពីការនិយាយតែឯងបែរទៅរកកិច្ចសន្ទនា.....9
យល់ដឹងអំពីបញ្ហា.....9
វឌ្ឍនភាពបច្ចុប្បន្ន.....11
អនុសាសន៍សម្រាប់គោលនយោបាយ.....13
អាទិភាពទី ៣៖  បទដ្ឋានច្បាប់ និងបទបញ្ញត្តិ៖ ផ្តល់ទំនុកចិត្តជូនអ្នកវិនិយោគ.....15
យល់ដឹងអំពីបញ្ហា.....15
វឌ្ឍនភាពបច្ចុប្បន្ន.....16
អនុសាសន៍សម្រាប់គោលនយោបាយ.....18
អាទិភាពទី ៤៖ អភិបាលកិច្ចល្អដើម្បីកំណើន.....20
យល់ដឹងអំពីបញ្ហា.....20
វឌ្ឍនភាពបច្ចុប្បន្ន.....21
អនុសាសន៍សម្រាប់គោលនយោបាយ.....24
**CAMFEBA –** អនុវត្តតួនាទីរបស់យើង.....26

# អក្សរកាត់

| | |
|---|---|
| AC | ក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| AC Law | ច្បាប់ប្រឆាំងអំពើពុករលួយ |
| ACB | អង្គភាពប្រឆាំងអំពើពុករលួយ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BFC | កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា |
| CAMFEBA | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CBA | ការចរចាអនុសញ្ញារួម |
| EESE | បរិយាកាសអំណោយផលដើម្បីសហគ្រាសមានចិរភាព |
| ETPC | គណៈកម្មាធិការគោលនយោបាយអប់រំ និងបណ្តុះបណ្តាល |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង |
| ILO | អង្គការអន្តរជាតិខាងការងារ |
| ITUC | សន្និសីទសហជីពអន្តរជាតិ |
| IR | ទំនាក់ទំនងវិជ្ជាជីវៈ |
| MoLVT | ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoU | អនុស្សារណៈនៃការយោគយល់គ្នា |
| NAA | អាជ្ញាធរសេនវកម្មជាតិ |
| NAC | មជ្ឈមណ្ឌលជាតិមជ្ឈត្តកម្ម |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| OECD | អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| TVET | ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |

# សេចក្តីផ្តើម

របាយការណ៍នេះ និងអនុសាសន៍សម្រាប់គោលនយោបាយក្នុងរបាយការណ៍នេះ ផ្តើមចេញពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល CAMFEBA ក្នុងគោលបំណងដើម្បីពង្រីកនូវវិសាលភាពរបស់សហព័ន្ធ ចេញពីបញ្ហាសង្គម និងការងា ទៅរកបញ្ហាកាន់តែធំថែមទៀតទាក់ទងនិងពាណិជ្ជកម្ម។ សហព័ន្ធមានគោលបំណងធំ គឺបង្កើនឯកសារគោលនយោបាយដោយផ្អែកទៅលើភស្តុតាង តាមរយៈការកំណត់រកកត្តាកំហិតសំខាន់ៗមកលើការរីកលូតលាស់របស់សហគ្រាស និងរៀបចំអនុសាសន៍សម្រាប់ធ្វើគោលនយោបាយដែលអាចផ្តល់ជំនួយទូលំទូលាយ និងអាចយកមកអនុវត្តបាន។

ការសិក្សាស្រាវជ្រាវដំបូងរបស់យើង ដែលបានអនុវត្តឡើងដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) និងបានពិគ្រោះយោបល់ជាមួយនឹងក្រុមហ៊ុនជាសមាជិក បានកំណត់ឃើញចំណុចសំខាន់ចំនួនបួន ដែលយើងយល់ថា ជាកត្តាកំហិតធំបំផុតលើការរីកលូតលាស់។ កត្តាទាំងនោះរួមមាន៖ *ទំនាក់ទំនងនៅកន្លែងធ្វើការ ជំនាញ អភិបាលកិច្ច និងបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិ។*

បន្ទាប់មក យើងបានផ្តួចផ្តើមការស្ទង់មតិថ្នាក់ជាតិ ដែលស្រាវជ្រាវកាន់តែស៊ីជម្រៅលើបញ្ហាទាំងនេះ តាមរយៈការសួរសំណួរថ្មីៗ ដែលរៀបចំឡើងក្នុងគោលបំណងជួយយើងបង្កើតនូវអនុសាសន៍សម្រាប់គោលនយោបាយដែលមានលក្ខណៈជាក់ស្តែង និងអាចយកទៅអនុវត្តបាន។

ដោយសហការជាមួយនឹង ILO និងប្រើប្រាស់វិធីសាស្ត្រ[1] *បរិយាកាសអំណោយផលដើម្បីសហគ្រាសមានចិរភាព* យើងបានរៀបចំដំណើរការពិគ្រោះយោបល់ ដើម្បីយល់ដឹងអំពីទស្សនៈវិស័យរបស់និយោជក និងកម្មករនិយោជិត នៅទូទាំងប្រទេសកម្ពុជា។ ការស្ទង់មតិថ្នាក់ជាតិរបស់យើងធ្វើឡើងលើកម្មករនិយោជិតចំនួន ២០០ នាក់ និងតំណាងក្រុមហ៊ុនចំនួន ៣០០ នាក់ នៅទូទាំងប្រទេសកម្ពុជា ពីខាងក្នុង និងពីខាងក្រៅសមាជិកភាពរបស់យើង ហើយយើងបានរៀបចំកិច្ចពិភាក្សាជាក្រុម ដើម្បីបំពេញបន្ថែមការស្ទង់មតិទាំងនេះ។ យើងបានស្វែងរកមតិយោបល់ពីវិស័យជាច្រើន ដែលមានសំខាន់ចំពោះសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងនៅថ្ងៃអនាគតរបស់កម្ពុជា ក្នុងនោះ មានវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) វិស័យកាត់ដេរ និងវិស័យកែច្នៃកសិកម្ម។ ដើម្បីបំពេញបន្ថែមការស្ទង់មតិទាំងនេះ យើងក៏បានធ្វើសិក្ខាសាលានៅទូទាំងប្រទេសជាមួយឥស្សរជនជាន់ខ្ពស់ផ្នែកពាណិជ្ជកម្មផងដែរ។

យើងបានស្រាវជ្រាវប្រមូលទិន្នន័យបឋម បូកនឹងការវិភាគគ្រប់ជ្រុងជ្រោយលើទិន្នន័យបន្ទាប់បន្សំដែលមានទាំងអស់លើបញ្ហាទាំងនេះ របាយការណ៍ដាច់ដោយឡែកចំនួន ១១៥ ដែលផ្តល់លទ្ធភាពបន្ថែមដល់យើងក្នុងការប្រៀបធៀបផ្អែកលើលក្ខណៈវិនិច្ឆ័យអន្តរជាតិ ដើម្បីកំណត់គោលនយោបាយសំខាន់ៗដែលត្រូវផ្តោតយកចិត្តទុកដាក់។

[1] កញ្ចប់ *បរិយាកាសអំណោយផលដើម្បីសហគ្រាសមានចិរភាព* បានរៀបចំឡើង ដោយផ្អែកលើក្របខណ្ឌសហគ្រាសមានចិរភាពចំនួន ១៧ របស់អង្គការអន្តរជាតិខាងការងារ ដែលបានទទួលការឯកភាពជាឯកច្ឆន្ទពីសំណាក់និយោជក កម្មករនិយោជិត និងរដ្ឋាភិបាល នៅក្នុងសន្និសីទអង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០០៧។

វិធីសាស្ត្រថ្មីដែលបូកទិន្នន័យបឋម ជាមួយទិន្នន័យបន្ទាប់បន្សំ ទស្សនៈរបស់កម្មករនិយោជិត និងក្រុមហ៊ុននេះ ព្រមទាំងលក្ខណៈវិនិច្ឆ័យអន្តរជាតិ បានជួយយើងបង្កើតការយល់ដឹងសំខាន់ៗ និងអនុសាសន៍ដែលអាចចាត់វិធានការបាន។ នៅពេលពិចារណារួមគ្នាជាមួយនឹង**របាយការណ៍បរិយាកាសអំណោយផលដើម្បីសហគ្រាសមានចិរភាព**របស់អង្គការអន្តរជាតិខាងការងារ ដែលជាការវិភាគរួមគ្រប់ជ្រុងជ្រោយលើបញ្ហាគោលនយោបាយកាន់តែទូលំទូលាយ និងដោយផ្អែកលើរបាយការណ៍នេះ យើងជឿជាក់ថា របាយការណ៍របស់យើងជាការត្រួតពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ដែលសេដ្ឋកិច្ចកម្ពុជាកំពុងប្រឈម។

របាយការណ៍នេះគឺជា"លទ្ធផលចុងក្រោយនៃការចាប់ផ្ដើម" និងបង្ករភាពងាយស្រួលមួយ ដោយបានធ្វើការវិភាគ និងរៀបចំជាអនុសាសន៍ ហើយយើងខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ធ្វើការរួមគ្នាដើម្បីសម្រេចនូវខ្លឹមសារនៃរបាយការណ៍នេះ។

**អនុប្រធានក្រុមប្រឹក្សាភិបាល**

**សាន់ដ្រា ដាមីកូ**

# អាទិភាពទី ១៖ បង្កើតជំនាញដើម្បីប្រកួតប្រជែង៖ ការអប់រំ ការបណ្តុះបណ្តាល និងការសិក្សារៀនសូត្រមួយជីវិត

ប្រជាជនកម្ពុជា ៣២ ភាគរយមានអាយុក្រោម ១៥ ឆ្នាំ ហើយមានយុវជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ ឈានចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងណា ការប្រែក្លាយឧត្តមភាពប្រជាសាស្ត្រទៅជាឧត្តមភាពសេដ្ឋកិច្ច ត្រូវការប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលដែលរឹងមាំ។ CAMFEBA ចាត់ទុកជំនាញមូលដ្ឋានខាងអក្ខរកម្ម ភាសា និងការគណនា គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ដើម្បីឲ្យពាណិជ្ជកម្មកម្ពុជារីកចម្រើន និងរុងរឿង ចាំបាច់ត្រូវការប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលដែលបំពេញបាននូវសេចក្តីត្រូវការផ្នែកផលិតភាព និងការបង្កើតថ្មីរបស់ពាណិជ្ជកម្ម ហេតុដូច្នេះ យើងត្រូវជំរុញកំណើននៃការវិនិយោគ ការអភិវឌ្ឍពាណិជ្ជកម្ម និងការងារ។

## យល់ដឹងអំពីបញ្ហា

កំណើនការងារនឹងបន្តកើតមានក្នុងសេដ្ឋកិច្ច ប្រសិនរាជរដ្ឋាភិបាលអនុវត្តផែនការពង្រីក និងធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់វិស័យផ្សេងៗ ដូចជា បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) និងការកែច្នៃស្រូវអង្ករ។ ទោះជាយ៉ាងណា ការស្ទង់មតិរបស់យើងបង្ហាញថា ក្រុមហ៊ុនជាង ៧៥ ភាគរយ យល់ថា កង្វះជំនាញកំពុងប៉ះពាល់ជាអវិជ្ជមានលើការរីកចម្រើនរបស់ក្រុមហ៊ុន។ ការងារ ដែលសេដ្ឋកិច្ចរបស់យើងបានបង្កើត ចាំបាច់ត្រូវបំពេញដោយប្រជាជនកម្ពុជា ប៉ុន្តែ ក្រុមហ៊ុនអាចរកកម្មករក្នុងស្រុក នៅក្នុងឧស្សាហកម្មធុនស្រាលបាន ដូចជា ក្នុងរោងចក្រផលិត ប៉ុន្តែតំណែងដែលត្រូវការជំនាញកាន់តែខ្ពស់ ជារឿយៗ ត្រូវបានកាន់កាប់ដោយបុគ្គលិកបរទេស។ ការដោះស្រាយបញ្ហានេះមានសារៈសំខាន់ ជាពិសេស បើគិតអំពីការធ្វើសមាហរណកម្មអាស៊ានបន្ថែមទៀតនោះ៖ **ការស្ទង់មតិរបស់យើងបានរកឃើញថា សហគ្រាសជិតពាក់កណ្តាលព្រួយបារម្ភអំពីលំហូរចូលដោយសេរីនៃកម្មករជំនាញ ទូទាំងតំបន់អាស៊ាន។**




ប្រភព៖ ផ្នែកប្រជាជននៃអង្គការសហប្រជាជាតិ "ព័ត៌មានប្រជាសាស្ត្រ"

តាមរយៈការធ្វើសកម្មភាពក្នុងពេលបច្ចុប្បន្ន ដើម្បីដោះស្រាយកង្វះខាតនៅក្នុងប្រព័ន្ធអប់រំ CAMFEBA ជឿជាក់ថា យើងអាចអភិវឌ្ឍជំនាញរបស់យុវជន និងកម្មករនិយោជិតថ្មីៗរបស់យើងបានយ៉ាងសកម្ម

*ការអភិវឌ្ឍប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលរឹងមាំ គឺជាកិច្ចអន្តរាគមន៍ដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីលើកកម្ពស់ឱកាសការងារ និងជំរុញកំណើន។*

***-- លោក Teh Sing អ្នកចាត់ការទូទៅក្រុមហ៊ុន Phnom Penh Beer Co., Ltd***

ដើម្បីបំពាក់បំប៉នពួកគេឲ្យចាប់យកឱកាសការងារថ្ងៃអនាគត។ ការធ្វើបែបនេះនឹងនាំទៅរកភាពរុងរឿងកាន់តែប្រសើរសម្រាប់បុគ្គល និងចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជាទាំងមូល។ ដើម្បីសម្រេចកិច្ចការនេះបាន ត្រូវមានប្រព័ន្ធអប់រំរឹងមាំផ្អែកលើទិន្នន័យច្បាស់លាស់ ដែលផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងសេចក្ដីត្រូវការកំពុងផ្លាស់ប្ដូរនៃវិស័យឯកជន។

| ស្ថិតិអប់រំចំណេះដឹងទូទៅនៅកម្ពុជាឆ្នាំ ២០០៨ | |
|---|---|
| អាត្រាអក្ខរកម្មមនុស្សពេញវ័យ(១៥+) | ៧៨ % |
| អត្រាចុះឈ្មោះថ្នាក់បឋមសិក្សា | ៩៨ % |
| អត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា | ៨០ % |
| អត្រាចុះឈ្មោះថ្នាក់មធ្យមសិក្សា | ៣៨ % |

ប្រភព៖ វិទ្យាស្ថានស្ថិតិ UNESCO (សូចនករអភិវឌ្ឍពិភពលោកលើអ៊ិនធឺណេត)។

ដើម្បីដោះស្រាយគម្លាតនៃជំនាញនាពេលបច្ចុប្បន្ន ត្រូវមានការវិភាគដែលមានលក្ខណៈជាប្រព័ន្ធលើនិន្នាការការងារ និងការព្យាករណ៍។ គេអាចសម្រេចបាននូវក្របខណ្ឌសម្រាប់ប្រមូលទិន្នន័យ ដើម្បីធ្វើការព្យាករណ៍អំពីជំនាញ ផ្គូរផ្គងអ្នកស្វែងរកការងារធ្វើជាមួយនឹងនិយោជក ព្រមទាំងបង្កើតប្រព័ន្ធអប់រំដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការដែលកំពុងវិវត្តន៍នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន។

ការសិក្សារបស់យើងតាមរយៈការស្ទង់មតិបានរកឃើញថា កម្មករជាង ៦៥ ភាគរយ បានបញ្ចប់យ៉ាងហោចណាស់សាលាមធ្យមសិក្សា ចំណែកឯស្ថិតិរបស់អង្គការ UNESCO ឆ្នាំ ២០០៨ រកឃើញថា អាត្រាចុះឈ្មោះថ្នាក់មធ្យមសិក្សាទាបជាង ៤០ ភាគរយ។ ជាទូទៅ ក្នុងការស្ទង់មតិ ក្រុមហ៊ុនពេញចិត្តចំពោះគុណភាពរបស់អ្នកផ្ដល់ការអប់រំ និងការបណ្ដុះបណ្ដាលជាពិសេស ទាក់ទងនឹងនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់សាកលវិទ្យាល័យ ប៉ុន្តែមិនសូវពេញចិត្តចំពោះសាលាថ្នាក់មធ្យមសិក្សាទេ ហើយម្យ៉ាងទៀត អ្នកផ្ដល់ការបណ្ដុះបណ្ដាលដែលមានគុណភាព ពុំមានចំនួនគ្រប់គ្រាន់ទេក្នុងកំរិតនេះ។




ប្រភព៖ការស្ទង់មតិថ្នាក់ជាតិរបស់ CAMFEBA

គម្រោងពង្រឹងវិស័យអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) អាចជួយសម្រួលការធ្វើសមាហរណកម្មយុវជន ទៅក្នុងទីផ្សារការងារ តាមរយៈការបង្កើតជំនាញអនុវត្តជាក់ស្ដែង ហើយទន្ទឹមនឹងនេះ ក៏ជួយផ្ដល់នូវជម្រើសផ្សេងៗដល់និស្សិតក្រៅពីការអប់រំជាទម្លាប់ធម្មតាដែលពុំបានផ្ដល់លក្ខណៈសម្បត្តិសមស្រប។ ទោះជាយ៉ាងណា អត្ថប្រយោជន៍ជាវិជ្ជមានបានកើតមាន ដោយសារចំនួនសិស្សបញ្ចប់ការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា បានកើនឡើងពី ៨៨.៣៦៧ នាក់ ក្នុងឆ្នាំ ២០០៧ ដល់ ១១៣.៦៤៨ នាក់ក្នុងឆ្នាំ ២០០៨[2] នេះបើយោងតាមការរកឃើញរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ប៉ុន្តែចំណុចនេះនៅតែជាអាទិភាពសម្រាប់ផ្នែកពាណិជ្ជកម្ម ហើយ**ការសិក្សាបានរកឃើញថា ការវិនិយោគលើ TVET ត្រូវការជាចាំបាច់ ដើម្បីធានាអំពីការទទួលបាននូវលទ្ធផលដែលមានគុណភាពកាន់តែខ្ពស់ថែមទៀត។**

[2] ILO. 2010.

ពាណិជ្ជកម្មកម្ពុជាចូលរួមលើកកម្ពស់ការសិក្សារៀនសូត្រដែលជាការប្រព្រឹត្តទៅពេញមួយជីវិត។ មូលដ្ឋានរឹងមាំផ្នែកភាសា អក្ខរកម្ម និងការគណនា ដែលចេះពីសាលា គឺជាគ្រឹះដើម្បីបន្តអភិវឌ្ឍចំណេះដឹងបន្តទៅទៀត។ ការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកគឺជាដំណើរការផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ព្រោះវាអាចកាត់បន្ថយកង្វះខាតជំនាញ ជួយលើកទឹកចិត្ត និងរក្សាបុគ្គលិកដែលមានទេពកោសល្យ និងកាត់បន្ថយចលនាផ្លាស់ប្តូរបុគ្គលិក។ ការប្តេជ្ញាអភិវឌ្ឍបុគ្គលិករបស់យើងត្រូវបាន បង្ហាញយ៉ាងច្បាស់ក្នុងការស្ទង់មតិនាពេលថ្មីៗនេះអំពីការវិនិយោគលើការអភិវឌ្ឍបុគ្គលិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum)។ បន្ថែមលើការស្ទង់មតិនោះ ការស្រាវជ្រាវរបស់យើងបានពិនិត្យកាន់តែស៊ីជម្រៅថែមទៀតលើបញ្ហា តាមរយៈការពិនិត្យមើលការបណ្តុះបណ្តាលដែលឧបត្ថម្ភដោយនិយោជក ផ្អែកលើទាំងទស្សនៈវិស័យរបស់កម្មករនិយោជិត ទាំងទស្សនៈវិស័យរបស់ក្រុមហ៊ុន។




ប្រភព៖ “The Global Competitiveness Report” WEF។ ផ្អែកលើការឆ្លើយតបរបស់មេដឹកនាំពាណិជ្ជកម្មចំពោះសំណួរដូចតទៅ៖ "វិធីសាស្ត្រទូទៅរបស់ក្រុមហ៊ុនផ្សេងៗក្នុងប្រទេសអ្នកចំពោះធនធានមនុស្សគឺ៖ (១=វិនិយោគតិចតួចលើការបណ្តុះបណ្តាល/ការអភិវឌ្ឍបុគ្គលិក។ ៧=ការវិនិយោគខ្លាំងដើម្បីទាក់ទាញ បណ្តុះបណ្តាល និងរក្សាបុគ្គលិកក្នុងក្រុមហ៊ុន ) ។

មានការរាយការណ៍ថា មានការបណ្តុះបណ្តាលផ្អែកលើការងារជាក់លាក់ ដូចជាជំនាញកុំព្យូទ័រមូលដ្ឋាន ជំនាញភាសា ជំនាញធ្វើម្ហូបអាហារ និងសេវាបម្រើអតិថិជនច្រើនជាងគេបំផុត។ ម្យ៉ាងទៀត យើងរកឃើញថា ការបណ្តុះបណ្តាលច្រើនតែធ្វើឡើងនៅក្នុងសហគ្រាសធំៗ សណ្ឋាគារ និងភោជនីយដ្ឋានរបស់កម្ពុជា ខណៈការរកឃើញការស្ទង់មតិបានបញ្ជាក់ថា ក្រុមហ៊ុនតូចៗទំនងជារងផលប៉ះពាល់អវិជ្ជមានថែមទៀត ដោយសារតែកង្វះនៃជំនាញ ធៀបនឹងក្រុមហ៊ុនធំៗ។

# វឌ្ឍនភាពបច្ចុប្បន្ន

ប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងទាក់ទងនឹងលទ្ធផលនៃការអប់រំចាប់ពីចុងទស្សវត្សទី៩០ មក។ អាត្រាអក្ខរកម្មបានកើនឡើងខ្លាំង ជាពិសេស ក្នុងចំណោមស្ត្រី ហើយកម្ពុជាកំពុងទទួលបានលទ្ធផលល្អនៅថ្នាក់តំបន់លើ "សន្ទស្សន៍អប់រំ" របស់អង្គការ UNESCO ជាសន្ទស្សន៍រាប់បញ្ចូលនូវអាត្រាអក្ខរកម្ម និងអត្រាចុះឈ្មោះចូលរៀន។ ជាការលើកទឹកចិត្ត ដោយចំនួនសាលារៀនកម្ពុជា បានកើនឡើង ៣០ភាគរយចាប់ពីឆ្នាំ២០០៣ មក ហើយចំណាយរបស់រដ្ឋលើវិស័យអប់រំផ្អែកលើភាគរយនៃផលិតផលក្នុងស្រុកសរុបបាន




ប្រភព៖ការស្ទង់មតិថ្នាក់ជាតិរបស់ CAMFEBA

កើនឡើងជិត១ភាគរយ ចាប់ពីឆ្នាំ២០០១ មក។ ប៉ុន្តែ បើធៀបនឹងចំណាយវិស័យអប់រំក្នុងប្រទេសដទៃ កម្ពុជាមានកម្រិតទាបជាងប្រទេសជិតខាង ខណៈដែលចំណុចនេះផ្ទាល់មិនមែនជាសូចនករនៃលទ្ធផលប្រកបដោយគុណភាពនោះទេ ហើយនាំឲ្យមានសំណួរចោទសួរថា តើចាំបាច់ត្រូវបង្កើនការវិនិយោគបន្ថែមទៀតឬយ៉ាងណា។

ក្រៅពីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស កម្ពុជាបានបង្កើនបទដ្ឋានគ្រូបង្រៀនផងដែរ។ នៅទីក្រុង គ្រូបង្រៀនត្រូវបញ្ចប់ការសិក្សា ១២ ឆ្នាំ មុនពេលទទួលការបណ្តុះបណ្តាលគរុកោសល្យ ចំណែកឯនៅតាមជនបទ គ្រូបង្រៀនត្រូវមានការសិក្សារយៈពេលប្រាំបួនឆ្នាំ។ របាយការណ៍របស់អង្គការ UNESCO ស្តីពីការអប់រំនៅកម្ពុជា បានស្នើកែតម្រូវបន្ថែមទៀតលើការបណ្តុះបណ្តាលគ្រូបង្រៀន តាមរយៈការបញ្ចូលវិធីសាស្ត្រគរុកោសល្យ និងការអនុវត្តបង្រៀនជាក់ស្តែងក្នុងសាលាបន្ថែមទៀត ហើយចង្អុលបង្ហាញថា ការបង្កើតសាលាបឋមសិក្សាគំរូនៅជិតសាលាគរុកោសល្យគឺជាជំហានវិជ្ជមាន។[4]

ក្នុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបច្ចុប្បន្នផ្តល់កម្មវិធីថ្នាក់ចម្រុះជាច្រើន ដូចជា បណ្តុះបណ្តាលបច្ចេកទេសគ្រឿងយន្តទូទៅ បច្ចេកវិទ្យាកុំព្យូទ័រ និងវិស្វកម្មស៊ីវិល។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមកំណត់គោលដៅផ្តល់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសតាមសហគមន៍ជនបទ ជាពិសេស ស្ត្រី ហើយកំពុងផ្តល់កម្មវិធីនានាជូនសិស្សក្មេងៗផងដែរ។ ការចំណាយនៅតែជាបញ្ហាប្រឈម ព្រោះឯកសារ គ្រឿងបរិក្ខា និងការថែទាំត្រូវការចំណាយច្រើន ហើយសម្ភារៈអប់រំបច្ចេកទេសអាចហួសសម័យយ៉ាងឆាប់រហ័ស ដោយសារតែការប្រែប្រួលលើទីផ្សារ និងការសម្របខ្លួនរបស់ឧស្សាហកម្ម។

ទោះជាយ៉ាងណា ការស្រាវជ្រាវរបស់យើងរកឃើញថា ក្រុមហ៊ុនជាងពាក់កណ្តាល យល់ថា កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់បំពេញបាននូវសេចក្តីត្រូវការរបស់សហគមន៍ពាណិជ្ជកម្មនៅឡើយទេ។ រាជរដ្ឋាភិបាលបានប្រកាសជាសាធារណៈថា រាជរដ្ឋាភិបាលចង់ធ្វើការជាមួយវិស័យឯកជន ដើម្បីបន្តអភិវឌ្ឍកម្មវិធីទាំងអស់នេះ ដែលទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់សហគមន៍ពាណិជ្ជកម្មកម្ពុជា។ ក្នុងការស្ទង់មតិបង្ហាញថា ក្រុមហ៊ុនចំនួន ៩០ ភាគរយ យល់ស្របឲ្យវិស័យឯកជនគួរចូលរួមថែមទៀតក្នុងការរៀបចំអាទិភាព និងកម្មវិធីសិក្សា TVET។




ការកែលំអរទាំងអស់នេះមានសារៈសំខាន់ ជាពិសេសចំពោះសហគ្រាសខ្នាតតូច និង/ឬសហគ្រាសនៅតាមជនបទ ដែលរាយការណ៍ថា បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារតែកង្វះជំនាញ។ ការបង្កើនជម្រើសសម្រាប់ការបណ្តុះបណ្តាល

3 មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ ២០០៩។

4 UNESCO-IBE. ឆ្នាំ ២០១១. World Data on Education 7th Edition.

ដែលមានទីតាំងងាយស្រួល ព្រមទាំងប្រើពេល និងចំណាយតិច សម្រាប់សហគ្រាសតូចៗ គឺជាចំណុចសំខាន់សម្រាប់ការអភិវឌ្ឍបន្ថែមទៀត។ CAMFEBA កំពុងជួយដោះស្រាយសេចក្តីត្រូវការនេះ ដោយផ្តល់ការបណ្តុះបណ្តាលក្នុងផ្នែកសំខាន់ៗ ដូចជា ធនធានមនុស្ស និងការគ្រប់គ្រង។ ម្យ៉ាងទៀត CAMFEBA នឹងបង្កើតគណៈកម្មាធិការស្តីពីគោលនយោបាយអប់រំ និងបណ្តុះបណ្តាល (ETPC) ដើម្បីឃ្លាំមើល និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តចំណុចទាំងអស់នៃគោលនយោបាយនេះ។ ETPC នឹងរាយការណ៍អំពីវឌ្ឍនភាពជូនក្រុមប្រឹក្សាភិបាល CAMFEBA រៀងរាល់ប្រាំមួយខែម្តង ដើម្បីអាចពិនិត្យឡើងវិញ និងវាយតម្លៃលើការអភិវឌ្ឍ។

កម្មវិធីសិក្សារបស់យើងបន្តផ្លាស់ប្តូរ ដោយផ្អែកលើទិន្នន័យសេដ្ឋកិច្ចត្រឹមត្រូវ និងនាពេលបច្ចុប្បន្ន ហើយកម្លាំងពលកម្ម គឺជាធាតុផ្សំមួយយ៉ាងសំខាន់ ក្នុងការបង្កើតកម្លាំងពលកម្មផ្អែកលើតម្រូវការចេញពីប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល។ ផែនការមេផ្នែកស្ថិតិរយៈពេល ១០ ឆ្នាំសម្រាប់កម្ពុជា បានបង្កើតវិថីឆ្ពោះទៅបង្កើនសមត្ថភាពខាងផ្នែកស្ថិតិរបស់រាជរដ្ឋាភិបាល ដើម្បីជួយឲ្យរាជរដ្ឋាភិបាលបំពេញមុខងារកាន់តែប្រសើរឡើងក្នុងវិស័យជាច្រើន។ ការរីកចម្រើនដ៏សំខាន់ៗ គឺការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និងការស្ទង់មតិលើកទី១ អំពីកម្លាំងពលកម្ម ក្នុងរយៈពេលជាងមួយទស្សវត្សនេះ បានសម្រេចរួចហើយ នៅមុនការត្រួតពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ ២០១២ ហើយតាមរយនេះ ការប្រើប្រាស់ព័ត៌មានទាំងនេះគឺជាមធ្យោបាយដ៏មានសារៈសំខាន់។

## អនុសាសន៍សម្រាប់គោលនយោបាយ

កម្ពុជាត្រូវតែបន្តពង្រឹង ធ្វើពិពិធកម្ម និងពង្រីកប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលរបស់ខ្លួន។ ការបន្តធ្វើបច្ចុប្បន្នភាព និងកំណែទម្រង់ប្រព័ន្ធអប់រំរបស់យើង ផ្អែកលើទិន្នន័យត្រឹមត្រូវ គឺជាការចាំបាច់ ដើម្បីធានាថា ជំនាញចេញពីប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបំពេញបាននូវសេចក្តីត្រូវការក្នុងផ្នែកសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ។ ដើម្បីភាពជោគជ័យនៃសេដ្ឋកិច្ច យើងត្រូវបន្តកែលំអរប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល ហើយ CAMFEBA នឹងបន្តគាំទ្ររាជរដ្ឋាភិបាលក្នុងសកម្មភាពទាំងនេះ។

**១. ធ្វើឲ្យប្រព័ន្ធអប់រំចំណេះដឹងទូទៅកាន់តែល្អប្រសើរឡើង**

- រាជរដ្ឋាភិបាលត្រូវធានាផ្តល់ការអប់រំមូលដ្ឋានសម្រាប់ប្រជាជនទាំងអស់ ដោយផ្តោតចម្បងលើជំនាញមូលដ្ឋានខាងអក្ខរកម្ម និងគណនា ដើម្បីសម្រេចបាននូវគ្រឹះរឹងមាំផ្នែកចំណេះដឹង។
- គួរពិចារណាសម្របឆ្នាំសិក្សាទៅនឹងសេចក្តីត្រូវការតាមរដូវកាលរបស់គ្រួសារកសិកម្ម (ដោយកំណត់ថ្ងៃឈប់សម្រាកនៅពេលប្រមូលផល។ល។) ដើម្បីលើកទឹកចិត្តចំពោះការបន្តសិក្សារៀនសូត្រក្នុងប្រព័ន្ធអប់រំ និងកាត់បន្ថយអាត្រាបោះបង់ចោលការសិក្សា។
- ដាក់បញ្ចូលការបណ្តុះបណ្តាលជំនាញអនុវត្តជាក់ស្តែង ការសិក្សារៀនសូត្រ សហគ្រិនភាព និងជំនាញបង្កើតថ្មី ទៅក្នុងកម្មវិធីសិក្សា និងជំរុញឲ្យវិស័យឯកជនចូលរួមក្នុងការរៀបចំគោលនយោបាយអប់រំ ក្នុងផ្នែកនានា ដូចជា បង្កើតកម្មវិធីសិក្សា និងកំណត់បទដ្ឋានសម្រាប់សិស្ស និងគ្រូបង្រៀន។

**២. ដើម្បីលើកកម្ពស់បទដ្ឋានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ យើងចាំបាច់ត្រូវលើកកម្ពស់កិច្ចសន្ទនា កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មានរវាងផ្នែកពាណិជ្ជកម្ម អ្នកអប់រំ អ្នកបណ្តុះបណ្តាល និងអ្នកបង្កើតគោលនយោបាយ។**

- បង្កើតដំណើរការបន្តកែសម្រួលកម្មវិធីសិក្សា ផ្អែកលើទិន្នន័យទីផ្សារការងារនាពេលបច្ចុប្បន្ន និងការព្យាករណ៍ ហើយធ្វើការតាមដាន វិភាគ និងផ្សព្វផ្សាយព័ត៌មានជាលក្ខណៈប្រព័ន្ធស្ដីពីការផ្គត់ផ្គង់ និងតម្រូវការនៃជំនាញ នៅលើទីផ្សារការងារនាពេលបច្ចុប្បន្ន សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង។
- អនុញ្ញាតឲ្យអ្នកតំណាងខាងវិស័យឯកជនចូលរួមក្នុងក្រុមប្រឹក្សាសាលា និងអង្គភាពបណ្ដុះបណ្ដាល។

**៣. រាជរដ្ឋាភិបាលគួរចាត់វិធានការបន្ទាន់ ដើម្បីលើកកម្ពស់ការបណ្ដុះបណ្ដាលឲ្យមានគុណភាពខ្ពស់ សម្រាប់ក្រុមហ៊ុននៅថ្នាក់តំបន់ និងធ្វើការផ្សព្វផ្សាយ។**

- ពង្រីកកម្រិត និងចំនួននៃភាពជាដៃគូ ការចុះធ្វើកម្មសិក្សា និងការហ្វឹកហ្វឺនកូនជាងរវាងសាលារៀន និងវិទ្យាល័យនៅតាមតំបន់ ជាមួយនឹងនិយោជកក្នុងស្រុក។
- ផ្ដល់ជម្រើសបណ្ដុះបណ្ដាលនៅតាមទីតាំងងាយស្រួល តម្លៃថោកសមល្មម និងអាចបត់បែនបាន។
- លើកកម្ពស់ទំនាក់ទំនងក្នុងចំណោមស្ថាប័ន ដើម្បីជៀសវាងការផ្ដល់កម្មវិធីជាន់គ្នា និងជំរុញប្រសិទ្ធិភាព។

**៤. បង្កើតភាពជាដៃគូរវាងក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុក និងអ្នកបណ្ដុះបណ្ដាល ដើម្បីធ្វើឲ្យការបណ្ដុះបណ្ដាលផ្ដោតលើ និងពាក់ព័ន្ធទៅនិងសេចក្ដីត្រូវការរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ដោយមានការអនុវត្តជាក់ស្ដែង ដែលរាប់បញ្ចូលទាំងការ ផ្ដល់បទពិសោធន៍ការងារ និងការរកការងារឲ្យធ្វើ ប្រសិនបើអាចធ្វើទៅបាន។**

- ខិតខំរៀបចំពិពណ៌ការងារក្រុមហ៊ុន ដើម្បីជួយឲ្យក្រុមហ៊ុនពាណិជ្ជកម្មធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងមនុស្សដែលនឹងក្លាយជាកម្មករនិយោជិតនាពេលខាងមុខ។
- ទទួលស្គាល់ថា ក្រុមហ៊ុនកម្ពុជាបានវិនិយោគច្រើនលើការបណ្ដុះបណ្ដាលនៅថ្នាក់សហគ្រាសរួចហើយ ពុំគួរដាក់បន្ទុកបន្ថែមមកលើក្រុមហ៊ុនកម្ពុជាទៀតទេ។

**៥. CAMFEBA អំពាវនាវឲ្យបង្កើតក្របខណ្ឌការងារថ្នាក់ជាតិដែលមានលក្ខណៈរួម និងផ្ដោតលើលទ្ធផល។**

- រៀបចំក្របខណ្ឌជាតិ TVET ដែលប្រើប្រាស់បទដ្ឋានសមត្ថភាពជាមូលដ្ឋាន។

***ក្នុងឋានៈជាអង្គការតំណាងពាណិជ្ជកម្មនៅកម្ពុជា CAMFEBA មានតួនាទីសំខាន់ក្នុងការរៀបចំគោលនយោបាយអប់រំ និងបណ្ដុះបណ្ដាល។***

# អាទិភាពទី២៖ការធ្វើឲ្យទំនាក់ទំនងនៅកន្លែងធ្វើការកាន់តែល្អប្រសើរ៖ ពីការនិយាយតែឯងបែរទៅរកកិច្ចសន្ទនា

CAMFEBA មានជំនឿមុតមាំថា កិច្ចសន្ទនាសង្គមយ៉ាងពេញលេញ និងពិតប្រាកដ ផ្អែកលើកិច្ចសហប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវ មិនមែនប្រឈមតទល់គ្នា គឺជាឧបករណ៍សំខាន់មួយក្នុងសហគ្រាសមានចិរភាព។ ការរៀបចំបរិយាកាសការងារឲ្យមានលក្ខណៈវិជ្ជមាន និងការសហការគ្នា អាចជួយលើកកម្ពស់ផលិតភាព និងការបង្កើតថ្មី ព្រមទាំងស្ថិរភាពកាន់តែល្អប្រសើរនៅកន្លែងការងារ និងផ្តល់អត្ថប្រយោជន៍ដល់និយោជកផង និងកម្មករនិយោជិតផង។

ភាពតានតឹងក្នុងបរិយាកាសនៃទំនាក់ទំនងវិជ្ជាជីវៈ រារាំងដល់ការវិនិយោគ និងធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះនៃការគោរពតាមបទដ្ឋានការងារអន្តរជាតិនៅក្នុងវិស័យកាត់ដេរ។ ភាពចលាចលនៃទំនាក់ទំនងនៅកន្លែងធ្វើការ ដែលបានកើតមានច្រើនក្នុងឆ្នាំ ២០១៣ និងចូលដល់ឆ្នាំ ២០១៤ នោះ គូសបញ្ជាក់នូវភាពចាំបាច់ត្រូវរៀបចំប្រព័ន្ធកិច្ចសន្ទនាសង្គម និងទំនាក់ទំនងនៅកន្លែងធ្វើការដ៏ក្មេងខ្ចីរបស់យើង។ *គេនឹងត្រូវការពេលវេលា ដើម្បីបញ្ជ្រាបទម្លាប់អនុវត្តនៃកិច្ចសន្ទនាសង្គមប្រកបដោយប្រសិទ្ធិភាព និងទទួលខុសត្រូវ និងដើម្បីកសាងប្រព័ន្ធរឹងមាំ ហើយទាំងនេះនៅតែជាការទទួលខុសត្រូវរបស់តួអង្គទាំងអស់។*

## យល់ដឹងអំពីបញ្ហា

កម្ពុជាបានចាប់ផ្តើមបង្កើតក្របខណ្ឌគតិយុត្តិដែលអាចជួយឲ្យមានបរិយាកាសនៃទំនាក់ទំនងល្អប្រសើររវាងនិយោជក និងកម្មករ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល (AC) ជាស្ថាប័នត្រីភាគីបានបង្កើតឡើងក្នុងឆ្នាំ ២០០៣ ដើម្បីដោះស្រាយវិវាទរួមអំពីសិទ្ធិ និងផលប្រយោជន៍ ដើរតួនាទីកណ្តាល និងសំខាន់នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ។ AC ដោះស្រាយរឿងក្តីបានជិត ៧០ភាគរយនៃវិវាទទាំងអស់ដែលបានបើកសវនាការ[5] ។ ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជាទទួលស្គាល់តួនាទីដ៏សំខាន់របស់ AC ក្នុងការដោះស្រាយវិវាទ និងប្តេជ្ញាបន្តគាំទ្រស្ថាប័ននេះ ព្រមទាំងធានាថាស្ថាប័ននេះនៅតែជាតួអង្គសំខាន់មិនលំអៀង ។




នាយកដ្ឋានដោះស្រាយវិវាទការងាររបស់ MoLVT គឺជាស្ថាប័នរាជរដ្ឋាភិបាលសំខាន់មួយចំពោះទំនាក់ទំនងវិជ្ជាជីវៈ។ ប្រសិទ្ធិភាពការងាររបស់នាយកដ្ឋានបានរីកចំរើនកាន់តែប្រសើរឡើង ប៉ុន្តែការទុកចិត្តពីសំណាក់កម្មករនិយោជិត និងនិយោជក នៅក្នុងដំណើរការផ្សះផ្សារ នៅតែជាបញ្ហាប្រឈម ហើយការធានាថា ការផ្សះផ្សាមានរចនាសម្ព័ន្ធល្អត្រឹមត្រូវនោះក៏នៅតែជាបញ្ហាប្រឈមផងដែរ។

---

[5] ILO. 2010. កម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ ២០១១-២០១៥.

បន្ថែមពីនេះទៀត នាយកដ្ឋានក៏ទទួលបន្ទុកក្នុងការចុះបញ្ជីសហជីព និងបញ្ជាក់ពី"ភាពជាតំណាង" និង"ភាពជាតំណាងបំផុត" របស់សហជីព។ តាមរយៈការចុះបញ្ជីនេះ អង្គការវិជ្ជាជីវៈក្លាយជានីតិបុគ្គល ដោយមានសិទ្ធិ និងការទទួលខុសត្រូវតាមច្បាប់។ ពីឆ្នាំ ១៩៩៧ ដល់ ២០១០ MoLVT បានចុះបញ្ជីសហជីពមូលដ្ឋានសរុប ១៧០០ ។ កម្មករនិយោជិតចំនួនប្រហែល ១ ភាគរយនៃចំនួនកម្មករសរុប បានបង្កើតជាសហជីព ឬសមាគម ដែលភាគច្រើននៅក្នុងវិស័យកាត់ដេរ។ ដោយ




ប្រភព៖ការស្ទង់មតិថ្នាក់ជាតិរបស់ CAMFEBA

ចំនួនប្រហែល ៦០ ភាគរយនៃកម្មករកាត់ដេរ ៤០០.០០០ នាក់នៅកម្ពុជាបានបង្កើតជាសហជីព វិស័យកាត់ដេរមានអត្រាចំនួនសហជីពខ្ពស់បំផុត ក្នុងចំណោមវិស័យទាំងអស់ ទោះជានៅប្រទេសអាស៊ីមួយណាក៏ដោយ។ ប៉ុន្តែ **សហជីពមានចំនួនច្រើន និងប្រកួតប្រជែងគ្នាជាបញ្ហាពិតប្រាកដចំពោះភាគីទាំងអស់ ហើយចាក់ឫសក្នុងអំពើពុករលួយ ការជ្រៀតជ្រែកក្នុងការគ្រប់គ្រង និងការចងសម្ព័ន្ធភាពជាមួយនឹងគណបក្សនយោបាយ។** ដូច្នេះ ជាមធ្យម មានសហជីពចំនួន ៥ ដែលជាញឹកញាប់ប្រកួតប្រជែងគ្នាក្នុងរោងចក្រមួយ ហើយកើតមានកូដកម្មច្រើន ដែលខុសច្បាប់ ដោយពួកគេមិនគោរពតាមនីតិវិធីច្បាប់។[6] គិតមកត្រឹមខែធ្នូ ឆ្នាំ ២០១៣ មានសហភាពចំនួន ១៣ សហព័ន្ធចំនួន ៨០ និងសហជីពមូលដ្ឋានចំនួន ៣០០៤ ដែលសកម្មក្នុងវិស័យកាត់ដេរ និងស្បែកជើង[7]។ សហជីពភាគតិច គឺជាបញ្ហាប្រឈមដ៏ធំចំពោះការធានាឲ្យមានចលនាសហជីពរួមគ្នា និងរួមគ្នាទទួលខុសត្រូវ ដែលអាចចូលរួមចំណែកប្រកបដោយប្រសិទ្ធិភាពក្នុងក្របខណ្ឌត្រីភាគី។

| ការកើនឡើងនៃសហជីពពីឆ្នាំ ២០១១ ដល់ ២០១២ | | |
|---|---|---|
| | ២០១១ | ២០១២ |
| សហជីពមូលដ្ឋាន | ១៧២៥ | ២៧៦៥ |
| សហព័ន្ធ | ៤១ | ៧៦ |
| សហភាព | ៨ | ១២ |

ប្រភព៖ CAMFEBA

CAMFEBA នៅតែជាតំណាងដ៏សំខាន់របស់និយោជកក្នុងទំនាក់ទំនងជាមួយនឹងសហជីព។ ចាប់ពីពេលបង្កើត ក្នុងខែកក្កដា ឆ្នាំ ២០០០ CAMFEBA បានក្លាយទៅជាអង្គការនិយោជកសំខាន់បំផុតនៅកម្ពុជា។ គិតមកត្រឹមខែកញ្ញា ឆ្នាំ ២០១៣ CAMFEBA តំណាងឲ្យនិយោជកជាង ១៥០០ ដែលយើងផ្តល់សេវាកម្មជាច្រើនជូនសមាជិក ក្នុងនោះ រួមមានការផ្សព្វផ្សាយព័ត៌មានថ្មីៗអំពីច្បាប់ និងបទប្បញ្ញត្តិ ការប្រឹក្សាយោបល់អំពីការគ្រប់គ្រងធនធានមនុស្ស និងច្បាប់ការងារ និងការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង។ ម្យ៉ាងទៀត CAMFEBA បានដើរតួនាទីយ៉ាងសំខាន់ធ្វើការស្រាវជ្រាវ និងតស៊ូមតិដើម្បីសមាជិក។ ក្រៅពីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន

[6] Nuon, V. និង Serrano, M. ឆ្នាំ ២០១០. "កសាងសហជីពនៅកម្ពុជា៖ ប្រវត្តិសាស្ត្រ បញ្ហាប្រឈម និងយុទ្ធសាស្ត្រ" ការិយាល័យ Freidrich Ebert Stiftung ដើម្បីកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅអាស៊ី.

[7] ស្ថិតិក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ ២០១៤

ចំពោះកម្មវិធីអប់រំ និងបណ្តុះបណ្តាលការស្រាវជ្រាវ និងអនុសាសន៍សម្រាប់គោលនយោបាយដែលបានធ្វើឡើងដោយ CAMFEBA បានត្រូវអនុវត្តយ៉ាងពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## វឌ្ឍនភាពបច្ចុប្បន្ន

សេចក្តីព្រាងច្បាប់សហជីពមានបញ្ញត្តិជាច្រើន ដែលនឹងលើកកម្ពស់កិច្ចសន្ទនាសង្គម ប្រសិនបើអនុវត្តបានត្រឹមត្រូវ តាមរយៈការជួយធ្វើឲ្យសហជីពក្លាយជាតួអង្គតំណាងកាន់តែមានប្រសិទ្ធិភាពថែមទៀត។ នេះជាជំហានសំខាន់ក្នុងការបង្កើតកិច្ចសន្ទនាយ៉ាងសកម្ម និងច្បាស់លាស់រវាងកម្មករ និយោជិត និងនិយោជក និងសហគមន៍ពលកម្មអន្តរជាតិ។ ទោះបីជាច្បាប់នេះរង់ចាំការអនុម័តចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១៣ ក៏ដោយ ក៏ប៉ុន្តែគេរំពឹងថានឹងមានពេលវេលាពិតប្រាកដដែលច្បាប់នេះនឹងចូលជាធរមានក្នុងឆ្នាំ ២០១៤។ **ការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធិភាពគឺជាអាទិភាពសំខាន់ចំពោះ CAMFEBA។**

អនុស្សារណៈយោគយល់គ្នាស្តីពីការលើកកម្ពស់ទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យកាត់ដេរ (MoU) ដែលបានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ២០១០ រវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហជីពជាច្រើន ហើយបន្តជាថ្មីក្នុងឆ្នាំ ២០១៣ ត្រូវការការអនុវត្តឲ្យបានតឹងរ៉ឹង និងទាន់ពេលវេលា។ ក្នុងអនុស្សារណៈនេះ ភាគីទាំងពីរបានព្រមព្រៀងប្រើប្រាស់នីតិវិធីមជ្ឈត្តកម្មចងកាតព្វកិច្ចរបស់ACចំពោះវិវាទអំពីសិទ្ធិ ការល្មើសច្បាប់និងអនុសញ្ញារួមដែលមានស្រាប់។ CAMFEBAស្វាគមន៍ចំពោះវឌ្ឍនភាពនេះ។ ទោះជាយ៉ាងណា យើងទទួលស្គាល់ថា កិច្ចសន្ទនាសង្គមពិតប្រាកដមិនចប់ត្រឹមចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះទេ ប៉ុន្តែត្រូវពឹងផ្អែកលើការអនុវត្តយ៉ាងពេញលេញ ហើយវឌ្ឍនភាពត្រង់ចំនុចនេះ នៅមានភាពយឺតយ៉ាវ។

*ពាណិជ្ជកម្មកម្ពុជាប្រតិបត្តិការនៅក្នុងបរិយាកាសប្រកួតប្រជែងខ្លាំងជាអន្តរជាតិ ហើយទំនាក់ទំនងមានស្ថិរភាពនៅកន្លែងធ្វើការគឺជាកត្តាសំខាន់កំណត់ភាពទាក់ទាញរបស់យើងចំពោះអ្នកវិនិយោគ* – **លោក Raymond Tam, នាយកគ្រប់គ្រង*Jei Wei (Cambodia) Garment Factory Co., Ltd***

ទោះបីជាមានវេទិកាសម្រាប់កិច្ចសន្ទនារវាងវិស័យសាធារណៈ និងឯកជន និងស្ថាប័ននិយ័តកម្មការងារត្រីភាគីក៏ដោយ ក៏ប៉ុន្តែកូដកម្មនៅតែកើតឡើងជាញឹកញាប់ ហើយភាគច្រើនគឺធ្វើខុសច្បាប់។ កូដកម្មទាំងនេះពុំពិចារណាអំពីក្តីកង្វល់របស់កម្មករនិយោជិតទាំងមូលនោះទេ ប៉ុន្តែធ្វើឡើងដើម្បីគោលបំណងរបស់ក្រុមឱកាសនិយម ដែលប្រើប្រាស់ឱកាសធ្វើកូដកម្ម ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនគិតអំពីសេចក្តីត្រូវការរបស់កម្មកររោងចក្រទាំងមូលទេ។ ស្ទើរគ្រប់កូដកម្មទាំងអស់ពុំបានអនុវត្តតាមនីតិវិធីច្បាប់ ពោលគឺ ត្រូវឆ្លងកាត់ការផ្សះផ្សា និងមជ្ឈត្តកម្មបន្ទាប់មក ការបោះឆ្នោតធ្វើកូដកម្ម និងសេចក្តីជូនដំណឹងប្រាប់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ [8] ម្យ៉ាងទៀត កូដកម្មខុសច្បាប់ ក្នុងនោះ មានបាតុកម្ម ការបិទផ្លូវ និងការចូលកាន់កាប់ក្រុមហ៊ុន

| ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរ (ជាប្រាក់ដុល្លារ អត្រាទាបបំផុតនៅថ្ងៃទី ១៥ ធ្នូ ២០១៣) | |
|---|---|
| ថៃ | ២៤៣.៥៧ |
| ចិន | ១៣៩.០៦ |
| កម្ពុជា | ៨០.០០ |
| វៀតណាម | ៧៧.៩៣ |
| ប៉ាគីស្ថាន | ៧៤.៦២ |
| ស្រីលង្កា | ៧៣.៨២ |
| បង់ក្លាដេស | ៧២.០៣ |
| ឥណ្ឌូនេស៊ី | ៧១.៥៦ |
| ឥណ្ឌា | ៦៩.៥០ |
| មីយ៉ាន់ម៉ារ | ៥៧.៦៨ |

ប្រភព៖ ILO

[8] ILO. 2010. Decent Work Country Programme Cambodia 2011-2015. P 23

ជាញឹកញាប់បង្អាក់ប្រតិបត្តិការពាណិជ្ជកម្មប្រចាំថ្ងៃ ដែលប៉ះពាល់មិនត្រឹមតែក្រុមហ៊ុន ឬវិស័យកាត់ដេរនោះទេ ប៉ុន្តែបានប៉ះពាល់ដល់សង្គមថែមទៀត ។ ក្នុងឆ្នាំនេះ កូដកម្មភាគច្រើនកើតមានអំពើហិង្សា និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។ CAMFEBA ស្វាគមន៍ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អង្គការនានា ដូចជា ILO ដើម្បីកសាងសមត្ថភាពក្នុងភាពជាដៃគូសន្ទនាសង្គម ប៉ុន្តែ *ជាការសំខាន់ដែលដៃគូទាំងអស់យល់ដឹងអំពីសិទ្ធិរបស់ខ្លួន ថែមទាំងការទទួលខុសត្រូវរបស់ខ្លួនក្នុងការគោរពតាមការព្រមព្រៀង និងធ្វើសកម្មភាពក្នុងរង្វង់ច្បាប់។ CAMFEBA ទទួលស្គាល់នូវសារៈសំខាន់របស់សហជីពជាផ្នែកនៃកិច្ចសន្ទនារវាងនិយោជិត និងនិយោជក ប៉ុន្តែសង្កត់ធ្ងន់លើសារៈសំខាន់នៃការតំណាងកម្មករពិតប្រាកដ ដោយមានការទទួលខុសត្រូវ និងគោរពច្បាប់។*

ដើម្បីដោះស្រាយបញ្ហាទាំងនេះ ត្រូវមានកិច្ចពិភាក្សាស្មោះត្រង់អំពីស្ថានការណ៍បច្ចុប្បន្ន និងឆន្ទៈសម្របសម្រួល និងការសន្យាគោរពតាមការព្រមព្រៀង ។ ក្នុងរយៈពេល ១២ ឆ្នាំកន្លងមកនេះ ILO បានចូលរួមយ៉ាងខ្លាំងជាមួយនឹងនិយោជក សហជីព និងរាជរដ្ឋាភិបាល។ ជាការពិត CAMFEBA ផ្តល់តម្លៃលើភាពជាដៃគូជាមួយនឹង ILO ។ កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់ ILO បានសម្រួលឲ្យមានការទទួលស្គាល់ជាសកលលើលក្ខខណ្ឌការងារល្អប្រសើរ និងប្រាក់ឈ្នួលខ្ពស់ដែលវិស័យកាត់ដេរនិងស្បែកជើងរបស់យើងបានផ្តល់ជូនកម្មករ។ បន្ទាប់ពីកិច្ចពិភាក្សាត្រីភាគីរវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)រាជរដ្ឋាភិបាល និងសហជីព ភាគីទាំងអស់បានព្រមព្រៀងតំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មកររោងចក្រកាត់ដេរ។ ការចូលរួមរបស់ភាគីក្នុងការចរចា នៅខណៈពេលមិនទាន់មានការកំណត់ប្រាក់ឈ្នួលអប្បបរមានៅថ្នាក់ជាតិជាទូទៅ បង្ហាញអំពីការប្តេជ្ញាចិត្តចំពោះបុព្វហេតុនេះ។ ជាអកុសល សហជីពមួយចំនួនបានធ្វើឲ្យប៉ះពាល់ដល់សមិទ្ធិផលនេះ តាមរយៈការបង្កកូដកម្មហិង្សា ដែលបាននាំឲ្យមនុស្សស្លាប់បាត់បង់ជីវិត និងរងរបួស។ **CAMFEBA មានជំនឿមុតមាំថា ដំណើរការនៃកិច្ចសន្ទនាសង្គម ដូចជាការចរចាលើប្រាក់ឈ្នួល អាចនាំទៅរកលទ្ធផលកាន់តែមានគុណភាពខ្ពស់ និងមានចិរភាព នៅពេលដំណើរការនោះផ្អែកលើភស្តុតាងរឹងមាំជាក់ស្តែង។**




ប្រភព៖ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) http://gmac-cambodia.org

# អនុសាសន៍សម្រាប់គោលនយោបាយ

កិច្ចសន្ទនាសង្គមមានគោលបំណងស្វែងរកដំណោះស្រាយរួម ដែលបង្កើតឡើងតាមរយៈការចូលរួមយ៉ាងពេញលេញពីភាគីទាំងអស់។ ភាគីទាំងអស់ត្រូវតែគោរពសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាសិទ្ធិ និងការទទួលខុសត្រូវរបស់សមភាគី ហើយទទួលយកថា ដំណើរការសហការនេះគឺពាក់ព័ន្ធនឹងការសម្រុះសម្រួលគ្នា។ ផលប៉ះពាល់អវិជ្ជមាននៃកូដកម្មហិង្សាបានសាយភាយហួសពីក្រុមហ៊ុនទៅទៀត។ ជាការពិត CAMFEBA គាំទ្រការអំពាវនាវរបស់ ILO ទៅកាន់អាជ្ញាធរ និងបាតុករ ដែលចូលរួមក្នុងកូដកម្មខុសច្បាប់ ឲ្យគោរពតាមច្បាប់ មានភាពអត់ធ្មត់ និងអនុវត្តគោលការណ៍នៃកិច្ចសន្ទនាសង្គម។[9] យើងចាំបាច់ត្រូវលើកកម្ពស់ និងកសាងកិច្ចសន្ទនារវាងដៃគូសង្គម ហើយបង្កើតទំនាក់ទំនងផ្អែកលើសេចក្តីសុចរិត និងការជឿទុកចិត្តគ្នា។ កិច្ចការនេះអាចសម្រេចបាន តាមរយៈការផ្តោតជាចម្បងលើបញ្ហាឯកភាពរួម និងខិតខំស្វែងរកនូវដំណោះស្រាយបែបស្ថាបនាចំពោះបញ្ហាខ្វែងគំនិតគ្នា។

១. CAMFEBA ស្នើរាជរដ្ឋាភិបាលដាក់ឲ្យអនុវត្តយ៉ាងពេញលេញនូវច្បាប់ថ្មីស្តីពីសហជីព និងធានាថា មានដាក់បញ្ចូលបញ្ញត្តិសម្រាប់ដកហូត និងលុបចោលការចុះបញ្ជីសហជីព នៅពេលដែល (១) ត្រូវបានចាត់ទុកថា គ្មានភាពជាតំណាងតាមផ្លូវច្បាប់ (២) មិនគោរពតាមច្បាប់ (៣) ចាប់ផ្តើមប្រើហិង្សា បំភិតបំភ័យ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ ច្បាប់ត្រូវចែងឲ្យបានច្បាស់អំពីនីតិវិធីធ្វើកូដកម្ម និងទណ្ឌកម្មចំពោះការមិនអនុវត្តតាមនីតិវិធីច្បាប់ ហើយមិនត្រូវសរសេរភាសាដែលមិនច្បាស់លាស់ និងធ្វើឲ្យភ័ន្តច្រឡំនោះទេ។

២. CAMFEBA គាំទ្រការគោរពតាមច្បាប់ ហើយលើកទឹកចិត្ត និងជួយសមាជិក ដើម្បីធានាថា សមាជិកគោរពតាមច្បាប់។ ទន្ទឹមនឹងនេះ CAMFEBA ទទូចស្នើសហជីពឲ្យគោរពតាមច្បាប់ស្តីពីការងារ ដោយអនុវត្តតាមនីតិវិធីសមស្រប មុនពេលចាប់ផ្តើមធ្វើសកម្មភាពផ្សេងៗ។

៣. CAMFEBA ស្នើរាជរដ្ឋាភិបាលពិនិត្យឡើងវិញលើបញ្ញត្តិស្តីពីម៉ោងធ្វើការ និងពិគ្រោះយោបល់ជាមួយនឹងដៃគូសង្គម ដើម្បីពិភាក្សាអំពីវិធីសាស្ត្រ ដែលអាចធ្វើវិសោធនកម្មលើបញ្ញត្តិទាំងនេះបាន (អាចតាមរយៈការព្រមព្រៀងដោយស្ម័គ្រចិត្ត ឬការដកប្រការចេញដោយស្ម័គ្រចិត្ត) ដើម្បីឆ្លុះបញ្ចាំងការពិតជាក់ស្តែង។ ចំណុចនេះអាចរាប់បញ្ចូលទាំងការធ្វើវិសោធនកម្មលើថ្ងៃបុណ្យផ្លូវការមួយចំនួនដើម្បីលើកកម្ពស់លទ្ធផលឲ្យប្រសើរថែមទៀតនៅកម្ពុជា។

៤. CAMFEBA បន្តគាំទ្រក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាយន្តការចម្បងក្នុងការដោះស្រាយវិវាទតាមច្បាប់។

៥. CAMFEBA អំពាវនាវឲ្យបង្កើនការបណ្តុះបណ្តាលជូនសហជីព ដើម្បីផ្តល់លទ្ធភាពដល់ពួកគេក្នុងការដើរតួនាទីឲ្យកាន់តែមានប្រសិទ្ធិភាព និងការទទួលខុសត្រូវថែមទៀត ក្នុងក្របខណ្ឌនៃទំនាក់ទំនងវិជ្ជាជីវៈ។

៦. ILO គួរបន្តផ្តល់យោបល់ និងការណែនាំដល់ដៃគូសង្គមទាំងអស់នៅកម្ពុជា ដើម្បីជួយយើងក្នុងការរៀបចំប្រព័ន្ធទំនាក់ទំនងវិជ្ជាជីវៈដែលមានការទទួលខុសត្រូវ និងផ្អែកលើការជឿទុកចិត្ត។

***CAMFEBA ជឿជាក់យ៉ាងមុតមាំថា កិច្ចសន្ទនាសង្គមដែលពេញលេញ និងពិតប្រាកដផ្អែកលើកិច្ចសហប្រតិបត្តិការដែលមានការទទួលខុសត្រូវ ជាជាងការប្រឈមតទល់គ្នា អាចជាឧបករណ៍សំខាន់មួយដើម្បីចិរភាព។***

[9] សេចក្តីថ្លែងការណ៍របស់ ILO ស្តីពីកូដកម្មនៅវិស័យកាត់ដេរ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣

# អាទិភាពទី ៣៖ បទដ្ឋានច្បាប់ និងបទប្បញ្ញត្តិ៖ ផ្តល់ទំនុកចិត្តជូនអ្នកវិនិយោគ

ច្បាប់ និងបទប្បញ្ញត្តិដែលរៀបចំឡើងល្អ បង្កើតបាននូវក្របខណ្ឌមួយដើម្បីធ្វើឲ្យសេដ្ឋកិច្ចទទួលបានជោគជ័យ។ ច្បាប់ និងបទប្បញ្ញត្តិពង្រឹងការប្រកួតប្រជែង កាត់បន្ថយចំណាយផ្លូវច្បាប់ បង្កើនប្រសិទ្ធិភាព កាត់បន្ថយតម្លៃ និងជំរុញឲ្យមានគំនិតច្នៃប្រឌិតថ្មី។ ម្យ៉ាងទៀត ការគោរពច្បាប់ និងការអនុវត្តច្បាប់ជាចំណុចសំខាន់នៃសង្គម ដែលជោគជ័យ។ ខណៈកម្ពុជាធ្វើសមាហរណកម្មសេដ្ឋកិច្ចបន្ថែមទៀតជាមួយនឹងប្រទេសជិតខាងក្នុងអាស៊ាន ការផ្តោតលើភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច និងសហគ្រាសរបស់យើងមានសារៈសំខាន់ចំពោះអនាគតប្រទេស។

ប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិល្អមានសារៈសំខាន់ក្នុងការសម្រេចបាននូវគោលដៅដែលកំណត់ក្នុង**យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន** របស់កម្ពុជា។ CAMFEBA រីករាយពេលឃើញវិស័យឯកជនរីកលូតលាស់ ដែលផ្តល់មកវិញនូវភាពខ្លាំងទាំងនេះ។ ក្នុងការសម្រេចគោលដៅទាំងនេះ ជាការសំខាន់ ដែលច្បាប់គាំទ្រគ្រប់សកម្មភាពទាំងអស់ក្នុងការធ្វើពាណិជ្ជកម្ម រាប់ទាំងការបង្កើត និងការចុះបញ្ជីពាណិជ្ជកម្ម ប្រតិបត្តិការប្រចាំថ្ងៃ ការគាំពារវិនិយោគ និងការដោះស្រាយវិវាទ។

## យល់ដឹងអំពីបញ្ហា

ខណៈកម្ពុជាមានអត្រាខ្ពស់នៃការចូលរួមពីកម្លាំងពលកម្ម ការងារតាមវិស័យក្នុងប្រព័ន្ធ ដែលផ្តល់ប្រាក់ឈ្នួលខ្ពស់ និងលក្ខខណ្ឌការងារល្អប្រសើរ មានចំនួនតិច។ ច្បាប់ការងារដែលបង្កើតដោយយកចិត្តទុកដាក់ ធានាថាពាណិជ្ជកម្មចុះបញ្ជី មានលទ្ធភាពអាចផ្តល់ការងារដែលមានគុណភាពបាន។



ប្រភព៖ការស្ទង់មតិថ្នាក់ជាតិរបស់ CAMFEBA

CAMFEBA បានធ្វើការស្ទង់មតិកម្មករនិយោជិតទាក់ទងនឹងទម្រង់កិច្ចសន្យាការងារដែលពួកគេចង់បាន។ យើងបានរកឃើញថា កម្មករចំនួនច្រើនលើសពីរដងចង់បានកិច្ចសន្យាមានថិរវេលាកំណត់ ឬកិច្ចសន្យាផ្ទាល់មាត់ ជាងកិច្ចសន្យាមានថិរវេលាមិនកំណត់។

CAMFEBA ទទួលស្គាល់ថា សូម្បីតែនៅក្នុងប្រទេសសេដ្ឋកិច្ចរឹងមាំ ក្រុមប្រជាជនងាយរងគ្រោះអាចមិនមានលទ្ធភាពរកបានចំណូលគ្រប់គ្រាន់។ ជាការពិត ក្រុមប្រជាជន ដូចជា កសិករធ្វើការខ្លួនឯង និងអ្នកបម្រើតាមផ្ទះ បន្តមានអត្រាភាពក្រីក្រខ្ពស់។ ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជាគាំទ្រចំពោះការផ្តល់ប្រព័ន្ធសន្តិសុខសង្គមសមល្មម ដែលអាចផ្តល់ជំនួយសមស្របចំពោះប្រជាជនផ្សេងៗ ដែលរាប់បញ្ចូលទាំងកម្មវិធីផ្សារភ្ជាប់នឹងការងារ និងការបង់ជំនួយជាសាច់ប្រាក់តាមគោលដៅ។ ដើម្បីឲ្យមានប្រសិទ្ធិភាព ប្រព័ន្ធទាំងនេះត្រូវតែរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ដើម្បីការពារអ្នកងាយរងគ្រោះបំផុតនៅក្នុងសង្គម ហើយទន្ទឹមនឹងនេះ បង្កើន

ការងារ ភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ច។ **អត្ថប្រយោជន៍ជាទូទៅពីកម្មវិធី និងសេវាកម្មរបស់រាជរដ្ឋាភិបាល ដូចជា របបសន្តិសុខសង្គម មានន័យថា ការទទួលខុសត្រូវលើហិរញ្ញវត្ថុត្រូវតែចែករំលែក។**

គោលនយោបាយពន្ធដារ ដែលបង្កើតឡើងដោយយកចិត្តទុកដាក់ ដែលកាត់បន្ថយចំណាយក្នុងការបំពេញបែបបទមានសារៈសំខាន់ចំពោះជម្រើសវិនិយោគផ្សេងៗ។ CAMFEBA ទទួលស្គាល់ថា ពេលពន្ធមានអត្រាកើនឡើងខ្ពស់ ហើយផលចំណេញហាក់បីដូចជាមានអត្រាទាប នឹងលើកទឹកចិត្តឲ្យពាណិជ្ជកម្មចាកចេញពីវិស័យផ្លូវការនឹងកើនឡើង។ ម្យ៉ាងទៀត នៅពេលគោលនយោបាយពន្ធដារដាក់បន្ទុកចំណាយខ្លាំង និងបន្ទុកចំណាយពេលវេលាមកលើពាណិជ្ជកម្ម វាអាចបន្ទុចបង្អាក់ដល់ការវិនិយោគ និងលើកទឹកចិត្តការប្រើប្រាស់មធ្យោបាយក្រៅផ្លូវការ។ ក្រៅពីរបបពន្ធដែលមានសមភាព ការធ្វើឲ្យដំណើរការផ្សេងៗមានលក្ខណៈផ្លូវការ ដូចជា ការប្រកាសពន្ធ និងការស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ គឺជាការលើកទឹកចិត្តឲ្យបង្កើនការវិនិយោគ។

# វឌ្ឍនភាពបច្ចុប្បន្ន

នៅលើ "សន្ទស្សន៍គុណភាពនៃបទប្បញ្ញត្តិ" របស់ធនាគារពិភពលោក ដែលវាស់វែងពីកម្រិតដែលប្រទេសផ្សេងអាចមានលទ្ធភាពបង្កើត និងអនុវត្តបទប្បញ្ញត្តិ ដែលលើកកម្ពស់វិស័យឯកជន កម្ពុជាបានទទួលចំណាត់ថ្នាក់ល្អប្រសើរឡើងចាប់តាំងពីឆ្នាំ ២០០៨ ហើយមានលទ្ធផលល្អនៅក្នុងតំបន់។ ទោះជាយ៉ាងណាពិន្ទុកាន់តែលំអិតដែលទាក់ទងនឹងការធ្វើពាណិជ្ជកម្មនៅកម្ពុជា គូសបញ្ជាក់ចំណុចដែលត្រូវកែលំអរ។

ខណៈដែលយើងធ្វើពិពិធកម្ម និងពង្រឹងសេដ្ឋកិច្ចរបស់យើង ជាការសំខាន់ត្រូវកាត់បន្ថយកត្តាដែលរារាំងដល់បង្កើតពាណិជ្ជកម្មថ្មីៗ តាមរយៈការកាត់បន្ថយនូវបន្ទុកហិរញ្ញវត្ថុ និងបន្ទុកពេលវេលាពាក់ព័ន្ធ។ ចំពោះជំហានដំបូងដ៏សំខាន់នេះ កម្ពុជាទទួលបានលទ្ធផលមិនសូវល្អទេ។ កម្ពុជាជាប់លេខ ១៨៤ ក្នុងចំណោម ១៨៩ ប្រទេស លើចំណាត់ថ្នាក់ទូទាំងសកលលោករបស់ធនាគារពិភពលោក ឆ្នាំ ២០១៤។ ជាភ័ព្វសំណាង នីតិវិធីចុះបញ្ជីទាំង ១១ ចំនុច មានលក្ខណៈងាយស្រួល។ ចំពោះនីតិវិធីពាណិជ្ជកម្មដទៃទៀតក៏អញ្ចឹងដែរ។ ឧទាហរណ៍ ការចុះបញ្ជីទ្រព្យត្រូវការរយៈពេលជាមធ្យម ៥៦ ថ្ងៃ ហើយត្រូវបំពេញនីតិវិធីដោយផ្ទាល់ចំនួន ៧ ដាច់ដោយឡែកពីគ្នា។[10] ទោះបីបានចុះបញ្ជីក៏ដោយ ប៉ុន្តែក៏នៅតែមានក្តីបារម្ភ ដោយសារតែកង្វះនៃការការពារចំពោះទ្រព្យរូបវន្ត និងកម្មសិទ្ធិបញ្ញា។ ការធ្វើឲ្យដំណើរការទាំងនេះមានលក្ខណៈងាយស្រួល ការពង្រឹងការការពារទ្រព្យ និងការធានាថា ប្រព័ន្ធច្បាប់របស់យើងផ្តល់នូវយន្តការដោះស្រាយ

| "ធ្វើពាណិជ្ជកម្ម"<br>ពិន្ទុ និងចំណាត់ថ្នាក់ ១ (ល្អបំផុត) ដល់ ១៨៩ | |
|---|---|
| **ពន្ធ** | |
| ចំណាត់ថ្នាក់សកល | ៦៥ |
| រយៈពេល (ម៉ោង/ឆ្នាំ) | ១៧៣ |
| អត្រាពន្ធសរុប (% នៃប្រាក់ចំណេញ) | ២១.៤ |
| **ការចាប់ផ្តើមពាណិជ្ជកម្ម** | |
| ចំណាត់ថ្នាក់សកល | ១៨៤ |
| នីតិវិធី (ចំនួន) | ១១ |
| រយៈពេល (ថ្ងៃ) | ១០៤ |
| ចំណាយ (% នៃចំណូលមធ្យមក្នុងមនុស្សម្នាក់) | ១៥០.៦ |
| **ការអនុវត្តកិច្ចសន្យា** | |
| ចំណាត់ថ្នាក់សកល | ១៦២ |
| រយៈពេល (ថ្ងៃ) | ៤៨៣ |
| ចំណាយ (% នៃការទាមទារ) | ១០៣.៤ |
| នីតិវិធី (ចំនួន) | ៤៤ |

ប្រភព៖ ធនាគារពិភពលោក. "ធ្វើពាណិជ្ជកម្ម"

[10] ធនាគារពិភពលោក. ធ្វើពាណិជ្ជកម្ម ឆ្នាំ ២០១៤-កម្ពុជា.

វិវាទដោយយុត្តិធម៌ និងមានប្រសិទ្ធិភាព នឹងលើកកម្ពស់បរិយាកាសសម្រាប់ពាណិជ្ជកម្ម និងបង្កើនភាពទាក់ទាញរបស់យើងជាទិសដៅសម្រាប់ការវិនិយោគ។

កម្ពុជាទទួលបានចំណាត់ថ្នាក់កាន់តែល្អប្រសើរផ្នែកច្បាប់ការងារ។ ដោយអនុញ្ញាតឲ្យប្រើកម្មករនិយោជិតតាមកិច្ចសន្យាការងារមានថិរវេលាកំណត់ នៅក្នុងពាណិជ្ជកម្ម និងកំណត់កម្រិតប្រាក់បំណាច់សមស្រប ក្រុមហ៊ុនអាចចាប់ផ្តើមជួលបុគ្គលិកភ្លាមៗខណៈដែលពាណិជ្ជកម្មចាប់ផ្តើមពង្រីក។ ទោះជាយ៉ាងណា ការកែសម្រួលចំពោះកម្រិតនៃការប្រើកិច្ចសន្យាមានថិរវេលាមានកំណត់ជាផ្នែកសំខាន់សម្រាប់ធ្វើការកែតម្រូវ ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់និយោជិតផង និងនិយោជកផង។

**សូចនករស្តីពីភាពតឹងរឹងនៃការងារ**

| | កម្ពុជា | IDN | LAO | THA | VNM |
|---|---|---|---|---|---|
| ត្រូវពិគ្រោះយោបល់ជាមួយភាគីទី ៣ មុននឹងបញ្ឈប់កម្មកររួមគ្នា(៩+)? | មាន | មាន | មាន | គ្មាន | មាន |
| កាតព្វកិច្ចត្រូវបណ្តុះបណ្តាល/កំណត់ការងារថ្មី មុនពេលបញ្ឈប់កម្មករ? | គ្មាន | មាន | គ្មាន | គ្មាន | មាន |
| វិធានអាទិភាពសម្រាប់ការបញ្ឈប់ការងាររួមគ្នា? | មាន | គ្មាន | គ្មាន | គ្មាន | មាន |
| ការហាមឃាត់មិនឲ្យកម្មករតាមកិច្ចសន្យាមានថិរវេលាកំណត់ធ្វើកិច្ចការអចិន្ត្រៃយ៍? | គ្មាន | មាន | គ្មាន | មាន | គ្មាន |
| រយៈពេលអតិបរមានៃកិច្ចសន្យាការងារមានថិរវេលាកំណត់ (គិតជាខែ) រាប់ទាំងការបន្តកិច្ចសន្យាទាំងអស់? | ២៤ | ៣៦ | គ្មានកំណត់ | គ្មានកំណត់ | ៧២ |
| ប្រាក់បំណាច់ (គិតជាសប្តាហ៍) ចំពោះការបញ្ឈប់ការងារបន្ទាប់ពីបានធ្វើការរយៈពេល ១ ឆ្នាំ | ២.១៤ | ១៧ | ៥.២០ | ១៥.០ | ៨.៦៧ |

ប្រភព៖ ធនាគារពិភពលោក. "ធ្វើពាណិជ្ជកម្មឆ្នាំ ២០១៣".
និយមន័យ៖ ឥណ្ឌូនេស៊ី (IDN) ឡាវ ( LAO) ថៃ (THA) វៀតណាម (VNM)

កម្ពុជាក៏មានវឌ្ឍនភាពក្នុងការលើកកម្ពស់សុខភាព និងសុវត្ថិភាពរបស់កម្មករផងដែរ។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិរបបជាតិសន្តិសុខសង្គម(NSSF) ហើយនិយោជកមានកាតព្វកិច្ចត្រូវចូលរួម ចាប់ពីឆ្នាំ ២០០៩ មក។ គិតមកត្រឹមខែមករា ឆ្នាំ ២០១៤ មានសហគ្រាសជាង ៤០០០ បានចុះបញ្ជីនៅ NSSF។ កំណែទម្រង់នាពេលខាងមុខនឹងធ្វើឲ្យគម្រោងនេះខិតកាន់តែជិតដូចកម្មវិធីដែលអនុវត្តក្នុងប្រទេសដទៃទៀត ដែលប្រមូលប្រាក់រួមចំណែកពីនិយោជិត និងផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារផង និងអត្ថប្រយោជន៍វេជ្ជសាស្ត្រទូទៅ និងប្រាក់សោធននិវត្តន៍ផង។ CAMFEBA ទទួលស្គាល់ថា ដើម្បីពង្រីកអត្ថប្រយោជន៍នេះ ជាការសំខាន់ត្រូវមានការចុះបញ្ជីសហគ្រាសច្រើនថែមទៀតដើម្បីបែងចែកបន្ទុកចំណាយនៃកម្មវិធីនេះឲ្យបានជាទូទៅ។

តួនាទីរបស់ CAMFEBA ក្នុង NSSF មានសារៈសំខាន់ចំពោះភាពជោគជ័យនៃកម្មវិធីនេះ ហើយគួរចាត់ទុក ជាគំរូសម្រាប់ការបញ្ចូលទស្សនៈនៃវិស័យឯកជននៅក្នុងដំណើរការរៀបចំគោលនយោបាយ។ តួនាទីរបស់យើងក្នុងក្រុមប្រឹក្សាភិបាលអនុញ្ញាតឲ្យយើងចូលរួមបង្កើត និងអនុវត្តកម្មវិធី និងផ្សព្វផ្សាយ NSSF យ៉ាងសកម្មជូនសមាជិករបស់យើង ដើម្បីចូលរួមកាន់តែច្រើន។ ការស្ទង់មតិថ្នាក់ជាតិរបស់យើងបង្ហាញថា ក្រុមហ៊ុនពាណិជ្ជកម្មដែលមិនមែនជាសមាជិក CAMFEBA ចំនួនតែ ៣៨ ភាគរយប៉ុណ្ណោះ បានចូលរួម NSSF ចំណែកឯសមាជិក CAMFEBA ដែលបានស្ទង់មតិដល់ទៅ ៩៨ ភាគរយបានចូលរួម។

បទដ្ឋានច្បាប់ និងបទប្បញ្ញត្តិមានអំណោយផល និងប្រសិទ្ធិភាពចំពោះការលូតលាស់របស់សហគ្រាសមានសារៈសំខាន់ចំពោះសមត្ថភាពរបស់ក្រុមហ៊ុនខ្ញុំក្នុងការពង្រីកប្រតិបត្តិការ និងបង្កើតការងារច្រើនថែមទៀតក្នុងសេដ្ឋកិច្ច – *សុក គីណាល់ អ្នកចាត់ការទូទៅនៃ* ***Aplus of Consulting Co.,Ltd.***

# អនុសាសន៍សម្រាប់គោលនយោបាយ

CAMFEBA ស្វាគមន៍ចំពោះច្បាប់ និងបទប្បញ្ញត្តិរឹងមាំ និងឆ្លាតវៃ ព្រោះច្បាប់ និងបទប្បញ្ញត្តិផ្តល់ស្ថិរភាព និងដូចការរំពឹងទុក ដែលប្រទេសយើងត្រូវការជាចាំបាច់។ ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលការពារប្រជាជនយើង មានសារៈសំខាន់ដើម្បីរក្សាសង្គមឲ្យមានយុត្តិធម៌ និងចុះសម្រុងគ្នា។ ទោះជាយ៉ាងណា ទាំងនេះគួររៀបចំឡើងផ្អែកលើចំណូលចិត្ត និងសមត្ថភាពរបស់បុគ្គលដែលទទួលរង ស្របតាមភាពពិតជាក់ស្តែងខាងសេដ្ឋកិច្ច។ ការសម្រួលការអភិវឌ្ឍ និងការលូតលាស់នៃពាណិជ្ជកម្ម ព្រមទាំងការការពារប្រកបដោយប្រសិទ្ធិភាពចំពោះការវិនិយោគ ទ្រព្យសម្បត្តិរូបវន្ត និងកម្មសិទ្ធិបញ្ញា គឺជាចំណុចដែលត្រូវកែលំអរបន្ថែមទៀត។

១. គាំទ្រ និងលើកទឹកចិត្តឲ្យគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាតិទាំងអស់ និងធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្កើនការយល់ដឹង និងការគោរពតាមច្បាប់។

២. លើកទឹកចិត្តរាជរដ្ឋាភិបាលឲ្យកំណត់គោលដៅច្បាស់លាស់ ដើម្បីកាត់បន្ថយបន្ទុកការិយាល័យធិបតេយ្យ និងរដ្ឋបាលមកលើក្រុមហ៊ុន។ ប្រសិនបើពុំទាន់មានទេ រាជរដ្ឋាភិបាលគួរចាប់ផ្តើមធ្វើការត្រួតពិនិត្យឡើងវិញលើបទប្បញ្ញត្តិឲ្យបានទៀងទាត់ ដោយមានការចូលរួមយ៉ាងពេញលេញពីសហគមន៍ពាណិជ្ជកម្ម ដោយផ្តោតជាពិសេសថាតើបទប្បញ្ញត្តិមានផលប៉ះពាល់មកលើពាណិជ្ជកម្មខ្នាតតូចយ៉ាងដូចម្តេច។

៣. កាត់បន្ថយកម្រៃចុះបញ្ជីពាណិជ្ជកម្ម និងបន្តកាត់បន្ថយរយៈពេលបង្កើតក្រុមហ៊ុន។

៤. សម្រួលដល់ការចូលរួមរបស់ក្រុមហ៊ុនក្នុងលទ្ធកម្មសាធារណៈ ឧទាហរណ៍ ដោយរៀបចំកញ្ចប់លទ្ធកម្មតូចៗ ដើម្បីឲ្យសហគ្រាសតូចអាចចូលរួមក្នុងដំណើរការដេញថ្លៃ។

៥. ដើម្បីស្មើរភាពពន្ធត្រូវអនុវត្តគ្រប់ផ្នែកទាំងអស់ក្នុងសង្គម។ ត្រូវខិតខំប្រឹងប្រែងដើម្បីកំហិតលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយពង្រីកសំណាញ់ពន្ធឲ្យបានធំបំផុតតាមដែលអាចធ្វើទៅបាន។ យើងតស៊ូមតិឲ្យកាត់បន្ថយពន្ធទាំងឡាយ ដែល "មិនគិតអំពីប្រាក់ចំណេញ" ពោលគឺ ពន្ធ ដែលត្រូវបង់ មិនថា ក្រុមហ៊ុនរកបានចំណេញ ឬអត់នោះទេ។

៦. ដាក់បញ្ចូលយន្តការពិគ្រោះយោបល់ជាមួយនិងវិស័យឯកជនក្នុងដំណើរការបង្កើតបទប្បញ្ញត្តិ ហើយដាក់ឲ្យអនុវត្តក្នុងក្របខណ្ឌ ដើម្បីការពារទល់និងការតាក់តែងបទប្បញ្ញត្តិមិនសមស្រប និងផ្តល់គណនេយ្យភាពថែមទៀតចំពោះការធ្វើសេចក្តីសម្រេច។

៧. ផ្សព្វផ្សាយអំពីកំណែទម្រង់បទប្បញ្ញត្តិណាក៏ដោយឲ្យបានច្បាស់លាស់ និងយ៉ាងសកម្មដល់សហគ្រាស។

*កំណែទម្រង់ចាំបាច់ត្រូវកាត់បន្ថយបន្ទុក ជាពិសេសលើពាណិជ្ជកម្មខ្នាតតូចៗ បង្កើនតម្លាភាពនៃបទប្បញ្ញត្តិ និងគាំទ្រសហគ្រិនភាព និងការចូលរួមក្នុងទីផ្សារ*

# អាទិភាពទី៤៖អភិបាលកិច្ចល្អដើម្បីកំណើន

អភិបាលកិច្ចល្អ ដោយមានស្ថាប័នឯករាជ្យរបស់រដ្ឋាភិបាល និងមានប្រសិទ្ធិភាព គឺផ្សារភ្ជាប់នឹងសេដ្ឋកិច្ចបច្ចុប្បន្ន និងនៅថ្ងៃអនាគតរបស់ប្រទេស។ សហគ្រាសមានចិរភាពត្រូវការច្បាប់ត្រឹមត្រូវ ហើយថែមទាំងការអនុវត្តច្បាប់ដែលអាចជឿទុកចិត្តបាន។ ជាផលប្រយោជន៍របស់ក្រុមហ៊ុនពាណិជ្ជកម្ម រាជរដ្ឋាភិបាល និងក៏ដូចប្រជាជន ត្រូវបន្តលើកកម្ពស់អភិបាលកិច្ចនៅក្នុងប្រទេសរបស់យើង ដើម្បីផ្តល់ស្ថិរភាពដល់ពាណិជ្ជកម្ម និងលើកទឹកចិត្តការវិនិយោគ និងការអភិវឌ្ឍពីខាងក្រៅចូលមកក្នុងប្រទេស។ CAMFEBA សូមប្តេជ្ញាចំពោះគោលដៅនេះ។

## យល់ដឹងអំពីបញ្ហា




ប្រភព៖ ធនាគារពិភពលោក ទិន្នន័យ “Governance Matters”.
និយមន័យ៖ កម្រិតដែលអំណាចសាធារណៈត្រូវបានយកមកប្រើដើម្បីផលប្រយោជន៍ឯកជន រាប់ទាំងអំពើពុករលួយក្នុងទម្រង់តូច និងធំ ព្រមទាំង "ការចាប់យក" ដោយបុគ្គលសំខាន់ និងក្រុមហ៊ុនឯកជន។ មាត្រដ្ឋាន -2.5 ដល់ 2.5 ដោយតម្លៃកាន់តែខ្ពស់ អភិបាលកិច្ចកាន់តែប្រសើរ។

ប្រព័ន្ធរដ្ឋបាល និងតុលាការយុត្តិធម៌ផ្តល់លទ្ធភាពដល់វិស័យឯកជនដំណើរការប្រកបដោយប្រសិទ្ធិភាព ហើយសេដ្ឋកិច្ចផ្អែកលើសាច់ប្រាក់របស់យើងបង្កើតរចនាសម្ព័ន្ធ ដែលលើកកម្ពស់ជាពិសេស ចំពោះអភិបាលកិច្ចល្អ។ ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជាយល់ច្បាស់អំពីចំណុចនេះ និងបន្តសម្តែងចេញនូវសេចក្តីប្រាថ្នាចង់បានអភិបាលកិច្ចកាន់តែល្អប្រសើរ ដូចក្នុងការស្ទង់មតិសកលរបស់ធនាគារពិភពលោក និងវេទិកាសេដ្ឋកិច្ចពិភពលោក។ ជាការពិត សហគ្រាសកម្ពុជាមានការព្រួយបារម្ភចំពោះកង្វះការអនុវត្តបទប្បញ្ញត្តិមានប្រសិទ្ធិភាព ជាជាងមានត្រឹមតែវត្តមាននៃបទប្បញ្ញត្តិនោះ។[11] ម្យ៉ាងទៀត ការស្ទង់មតិផ្ទាល់របស់យើងបានបង្ហាញថា ក្រុមហ៊ុនពាណិជ្ជកម្មយល់ថា អភិបាលកិច្ចកាន់តែល្អប្រសើរជាវិធីសំខាន់បំផុតដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់យើងរីកចម្រើន។ ខណៈការសិក្សាស្រាវជ្រាវឆ្នាំ ២០១២ ដោយ OECD បង្ហាញថា ក្រុមហ៊ុនបរទេសដែលប្រតិបត្តិការនៅកម្ពុជាពុំជួបផលវិបាកទេ បើធៀបនឹងក្រុមហ៊ុនកម្ពុជា[12] អង្គភាពព័ត៌មានអ្នកសេដ្ឋកិច្ច (Economist Intelligence Unit) ប៉ាន់ប្រមាណថា GDP ប្រចាំឆ្នាំ ១០% បានបាត់បង់ដោយសារអំពើពុករលួយ។[13]

ការស្រាវជ្រាវរបស់យើងលើផលវិបាកឃើញថា ការមិនបង់កម្រៃសម្រួលការងារបណ្តាលឲ្យផ្តល់សេវាកម្មយឺតយ៉ាវ ឬមិនទទួលបានសេវាកម្ម ចំពោះក្រុមហ៊ុន ៧០ ភាគរយ។ ធាតុផ្សំសំខាន់ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវអនុវត្តការជ្រើសរើស

[11] វេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ 2012. របាយការណ៍សកលលោកស្តីពីភាពប្រកួតប្រជែង ឆ្នាំ ២០១២-២០១៣.
[12] OECD. ឆ្នាំ ២០១២. ផ្លូវអភិវឌ្ឍជំនាញនៅអាស៊ី. OECD; LEED.
[13] អង្គភាពព័ត៌មានអ្នកសេដ្ឋកិច្ច (EIU). ឆ្នាំ ២០១២. ព័ត៌មានអំពីកត្តាហានិភ័យនៅកម្ពុជា. Economist Group (ទីក្រុងឡុង).

និងតំឡើងមុខតំណែងផ្អែកលើគុណសម្បត្តិរបស់មន្ត្រីរាជការ ដែលរៀបចំ និងផ្តល់សេវាសាធារណៈ ហើយដាក់ពួកគេឲ្យស្ថិតក្រោមក្រមប្រតិបត្តិ លក្ខខណ្ឌក្នុងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានដទៃទៀត និងវិធានការដាក់ពិន័យសមស្រប។ ការកែលំអរប្រព័ន្ធតុលាការ ក៏ជាបញ្ហាបន្ទាន់ជាពិសេសផងដែរ។

ប្រព័ន្ធតុលាការមានសមធម៌ជាក្តីកង្វល់សំខាន់នៅកម្ពុជា ដែលចំណាយខ្ពស់ក្នុងការដាក់ពាក្យបណ្តឹងក្រោមក្រមនីតិវិធីរដ្ឋប្បវេណីថ្មី បានរារាំងប្រជាជនកម្ពុជាជាច្រើននាក់មិនឲ្យប្រើប្រាស់សេវានេះ។ ជាការពិត ការស្រាវជ្រាវរបស់ CAMFEBA រកឃើញថា ក្រុមហ៊ុនតូចៗទទួលរងផលប៉ះពាល់ខ្លាំងបំផុត ដោយសារបរិយាកាសពាណិជ្ជកម្មមិនអាចរំពឹងទុកបាន ពេលខ្វះអភិបាលកិច្ចល្អ និងរកឃើញថា ការរក្សាទំនាក់ទំនងល្អ មានស្ថិរភាពជាមួយនឹងមន្ត្រីមូលដ្ឋាន ជាមូលហេតុចម្បងដែលក្រុមហ៊ុនតូចៗបង់សំណូក។[14] ចំណុចនេះបង្កការខូចខាតដល់ពាណិជ្ជកម្ម ព្រោះវាប៉ះពាល់ដល់ទំនុកចិត្តថាតើទ្រព្យសម្បត្តិរូបវន្ត និងកម្មសិទ្ធិបញ្ញា ព្រមទាំងការវិនិយោគរបស់ពួកគេនឹងត្រូវបានការពារឬយ៉ាងណា។

ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលទ្ធកម្មមានតម្លាភាព មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ពាណិជ្ជកម្មទេគឺថែមទាំងធានាថា ធនធានរបស់ប្រជាជនត្រូវបានយកមកប្រើប្រាស់យ៉ាងត្រឹមត្រូវ។ ទោះជាយ៉ាងណា ក្រុមហ៊ុនកម្ពុជាជាង ៧០ ភាគរយ យល់ឃើញថា ទំនាក់ទំនងផ្ទាល់ខ្លួនគឺជាកត្តាសំខាន់។[15] ចំណុចនេះធ្វើឲ្យលទ្ធកម្មកាន់តែស្មុគស្មាញចំពោះក្រុមហ៊ុនដែលដេញថ្លៃចាញ់ផង និងក្រុមហ៊ុនដែលឈ្នះការដេញថ្លៃផង។ របាយការណ៍ **ពិន្ទុបរិយាកាសពាណិជ្ជកម្មនៅខេត្ត** ឆ្នាំ ២០០៩ នៅកម្ពុជា ណែនាំឲ្យប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យលទ្ធកម្មសាធារណៈនៅកម្ពុជា។ ម្យ៉ាងទៀត របាយការណ៍នេះណែនាំឲ្យអនុវត្តប្រព័ន្ធសុចរិត និងការត្រួតពិនិត្យផ្លូវច្បាប់ពេលចុះកិច្ចសន្យាជាមួយនឹងភ្នាក់ងារដើម្បីសម្រួលប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។

## វឌ្ឍនភាពបច្ចុប្បន្ន

| | ក្នុងរយៈពេល ២ ឆ្នាំកន្លងមកនេះ តើកម្រិតនៃអំពើពុករលួយមានការផ្លាស់ប្តូរយ៉ាងដូចម្តេច? * | | តើរដ្ឋាភិបាលរបស់អ្នកកាត់បន្ថយអំពើពុករលួយប្រកបដោយប្រសិទ្ធិភាពយ៉ាងដូចម្តេច? ** | |
|---|---|---|---|---|
| | ធ្លាក់ចុះ | កើនឡើង | មានប្រសិទ្ធិភាព | គ្មានប្រសិទ្ធិភាព |
| **កម្ពុជា** | ៥១% | ២៤ % | ៥៧ % | ១៥ % |
| **បង់ក្លាដេស** | ២៧ % | ៦០ % | ២៥ % | ៣២ % |
| **ឥណ្ឌូនេស៊ី** | ៨ % | ៧១ % | ១៦ % | ៦៥ % |
| **ថៃ** | ៩ % | ៦៦ % | ២៥ % | ៤២ % |
| **វៀតណាម** | ១៨ % | ៥៥ % | ២៤ % | ៣៨ % |

ប្រភព៖ អង្គការតម្លាភាពអន្តរជាតិ "ប៉ារ៉ូម៉ែត្រអំពើពុករលួយលើសកលលោក (GCB)" ឆ្នាំ ២០១៣.

*បញ្ចូលប្រភេទ GCB "ដែលធ្លាក់ចុះខ្លាំង" ជាមួយនឹង "ដែលធ្លាក់ចុះតិច" និង "ដែលកើនឡើងខ្លាំង" និង "ដែលកើនឡើងតិច"។

**បញ្ចូលប្រភេទ GCB "មានប្រសិទ្ធិភាពណាស់" ជាមួយនឹង "មានប្រសិទ្ធិភាព" និង "គ្មានប្រសិទ្ធិភាព" និង "គ្មានប្រសិទ្ធិភាពសោះ"។

[14] Business Anti-Corruption Portal. (undated).

[15] IFC និងមូលនិធិអាស៊ី. ឆ្នាំ ២០០៩. "ពិន្ទុខេត្តនៅកម្ពុជា - ឆ្នាំ ២០០៩".

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការច្បាស់លាស់ ដើម្បីលើកកម្ពស់អភិបាលកិច្ច និងធ្វើឲ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ល្អប្រសើរឡើងនៅក្នុងរបាយការណ៍សកលលោកស្តីពីភាពប្រកួតប្រជែង ហើយការស្រាវជ្រាវដោយអង្គការតម្លាភាពអន្តរជាតិ បង្ហាញនូវទំនុកចិត្តយ៉ាងពិតប្រាកដលើប្រសិទ្ធិភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។

រាជរដ្ឋាភិបាល បានធ្វើកំណែទម្រង់ ដើម្បីបង្កើតនីតិវិធីរួម និងងាយស្រួល សម្រាប់សេវាកម្មជាច្រើន។ ជោគជ័យនៃការធ្វើឲ្យនីតិវិធីមានលក្ខណៈសាមញ្ញដោយក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ ២០០៧ បានកាត់បន្ថយពេលវេលា និងថ្លៃចំណាយចុះបញ្ជីពាណិជ្ជកម្ម។ ដូច្នេះ ចំនួនក្រុមហ៊ុនដែលបានចុះបញ្ជី បានកើនឡើងទ្វេរដងពីឆ្នាំ ២០០៥ ដល់ ២០០៨។ លើសពីនេះ ក្រសួងរាជរបស់រដ្ឋាភិបាលជាច្រើនបច្ចុប្បន្ននេះ បានផ្សព្វផ្សាយកម្រៃសេវាកម្មផ្លូវការ។ ជាអកុសល ក្រុមហ៊ុនពាណិជ្ជកម្មក្នុងការស្ទង់មតិចំនួន ៧១.៣ ភាគរយ ពុំបានដឹងអំពីចំណុចនេះទេ ហើយវឌ្ឍនភាពក្នុងផ្នែកមួយចំនួនមានភាពយឺតយ៉ាវ។ ក្នុងឆ្នាំ ២០១៣ កម្ពុជាបានធ្វើឲ្យមានការលំបាកក្នុងការចាប់ផ្តើមពាណិជ្ជកម្មដោយកំណត់លក្ខខណ្ឌផែកឈ្មោះក្រុមហ៊ុន និងបង្កើនថ្លៃចំណាយស្នើសុំការឯកភាពលើឯកសារចុះបញ្ជី និងការចុះបញ្ជីក្រុមហ៊ុនជាមួយនិងអ្នកកាន់បញ្ជីក្រុមហ៊ុន។ យោងតាម "ការស្ទង់មតិក្នុងចំណោមរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច ឆ្នាំ ២០១២" បានឲ្យដឹងថា ការផ្សាយព័ត៌មានរដ្ឋាភិបាលលើអ៊ិនធឺណេត និងការធ្វើស្វ័យប្រវត្តិកម្មនៃដំណើរការការិយាល័យ ជាធាតុផ្សំចម្បងនៃការអភិវឌ្ឍមានចិរភាព នៅក្នុងបណ្តាប្រទេសទូទាំងពិភពលោក។ លើសពីនេះ ចំណាត់ថ្នាក់ទាបរបស់កម្ពុជាលើ "សន្ទស្សន៍សេវាកម្មលើអ៊ិនធឺណេតឆ្នាំ ២០១២" ទុកឱកាសជាច្រើនសម្រាប់ធ្វើការកែលំអរ។

| សន្ទសន៍ភាពប្រកួតប្រជែងសកលលោក | | | |
|---|---|---|---|
| | ២០០៧-៨ | ២០១០-១១ | ២០១៣-១៤ |
| **សិទ្ធិកម្មសិទ្ធិ** | ៣.៥៩ | ៣.៥១ | ៣.៦៤ |
| **បន្ទុកនៃបទប្បញ្ញត្តិរដ្ឋាភិបាល** | ៣.០៩ | ៣.៣៦ | ៣.៥១ |
| **ការការពារកម្មសិទ្ធិបញ្ញា** | ២.៦៦ | ២.៨៤ | ៣.១៧ |
| **ប្រសិទ្ធិភាពនៃក្របខណ្ឌច្បាប់ក្នុងការដោះស្រាយវិវាទ** | -- | ៣.៥៨ | ៣.៥៥ |

ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក

ស្ថាប័ន និងច្បាប់ជាច្រើនបានបង្កើតឡើងនៅកម្ពុជា ដើម្បីជួយកាត់បន្ថយ និងទប់ស្កាត់អំពើពុករលួយក្នុងជួររដ្ឋាភិបាល។ ការបង្កើតច្បាប់ប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ជាការបង្កើតយ៉ាងសំខាន់ក្នុងចំណោមស្ថាប័ន និងច្បាប់ដទៃទៀត។ ច្បាប់ប្រឆាំងអំពើពុករលួយកំណត់ទណ្ឌកម្មលើអ្នកទទួល និងអ្នកបង់កម្រៃសម្រួល ហើយតម្រូវឲ្យមន្ត្រីរាជរដ្ឋាភិបាលប្រកាសទ្រព្យសម្បត្តិរៀងរាល់ពីរឆ្នាំម្តង។ ការកាត់ទោសឆ្នាំ ២០១១ លើមន្ត្រីជាន់ខ្ពស់ខេត្តមួយរូប ដែលបានរំលោភលើច្បាប់នេះ ជាព្រឹត្តការណ៍លើកទឹកចិត្ត។[16] ម្យ៉ាងទៀត គណបក្សនយោបាយ ៦ នៃគណបក្សនយោបាយ ៨ បានចុះហត្ថលេខាលើពាក្យសន្យាប្រឆាំងអំពើពុករលួយ ដែលរាប់បញ្ចូលការពង្រីកការប្រកាសទ្រព្យសម្បត្តិបច្ចុប្បន្ន ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយឲ្យកាន់តែខ្លាំងក្លា និងការផ្តោតជាពិសេសលើអភិបាលកិច្ចល្អក្នុងវិស័យអប់រំ និងការជ្រើសរើសមន្ត្រីរាជការរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណា អង្គភាពប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាលបង្កើតនូវឥទ្ធិពលតិចតួច ដោយសារតែការយល់ដឹងនៅទាបក្នុងចំណោម

[16] ព្រះរាជអាជ្ញា ពុង ចន្ទសូយុទ្ធារ៉ា ថ្លែងថា លោក តុប ចន្ទសេរីវុធ អតីតព្រះរាជអាជ្ញានៅខេត្តពោធិសាត់ ត្រូវបានកាត់ឲ្យមានទោសពីបទជំរិតប្រាក់ និងទទួលសំណូក ដើម្បីដោះលែងអ្នកជួញដូរឈើ។ Wall Street Journal. ឆ្នាំ ២០១១.

សាធារណជន ការភ័យខ្លាចអំពីការប្រកាសអំពីអំពើពុករលួយទាំងក្នុងវិស័យសាធារណៈ និងឯកជន ការយល់ថា អង្គភាពប្រឆាំងអំពើពុករលួយមានភាពលំអៀង។[17]

ស្ថាប័នពីរផ្សេងទៀត គឺអាជ្ញាធរសវនកម្មជាតិ និងមជ្ឈមណ្ឌលជាតិមជ្ឈត្តកម្ម ត្រូវបានបង្កើតឡើងដើម្បីជួយឲ្យមានដំណើរការល្អ និងទំនុកចិត្តលើរដ្ឋាភិបាល តាមរបៀបពីរខុសគ្នា។ ក្នុងឆ្នាំ ២០០២ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរសវនកម្មជាតិ ទទួលបន្ទុកធ្វើសវនកម្មពីខាងក្រៅលើទីភ្នាក់ងាររដ្ឋាភិបាល និងកសាងស្ថាប័នសវនកម្មកំពូល។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិមជ្ឈត្តកម្មគឺជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទី១ របស់កម្ពុជា។ ដោយមានមជ្ឈមណ្ឌលជាតិមជ្ឈត្តកម្ម ក្រុមហ៊ុនអាចដោះស្រាយវិវាទពាណិជ្ជកម្ម បានកាន់តែឆាប់រហ័ស និងចំណាយតិចជាងប្រព័ន្ធតុលាការ ដោយកសាងទំនុកចិត្តថា វិធាននឹងត្រូវយកមកអនុវត្ត និងផ្តល់សន្តិសុខ និងស្ថិរភាពដែលក្រុមហ៊ុនពាណិជ្ជកម្មត្រូវការដើម្បីធ្វើការវិនិយោគ។ CAMFEBA ទទួលស្គាល់ថា អង្គភាពប្រឆាំងអំពើពុករលួយ កំពុងធ្វើការងារយ៉ាងល្អ ហើយមានប្រសិទ្ធិភាព។ ប៉ុន្តែ ដើម្បីសម្រេចបាននូវកម្រិតនៃការផ្លាស់ប្តូរត្រូវផ្អែកលើអង្គភាពនេះ ហើយត្រូវធ្វើការវិនិយោគបន្ថែមទៀត។

> *ខ្ញុំសូមស្វាគមន៍គំនិតផ្តួចផ្តើមរបស់ **CAMFEBA** ក្នុងការរៀបចំយន្តការរាយការណ៍ដើម្បីផ្តល់លទ្ធភាពដល់ក្រុមហ៊ុន ជាពិសេស ក្រុមហ៊ុនតូចៗ រាយការណ៍អំពីអំពើពុករលួយដោយមិនបញ្ចេញឈ្មោះ។ --*
> ***ឯ.ឧ ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ***

CAMFEBA ទទួលស្គាល់តួនាទីរបស់វិស័យឯកជន ក្នុងការលើកកម្ពស់អភិបាលកិច្ច ប៉ុន្តែទទួលស្គាល់ផងដែរនូវគ្រោះថ្នាក់ចំពោះបុគ្គល ក្នុងករណីគ្មានកិច្ចការពារផ្លូវច្បាប់ចំពោះអ្នករាយការណ៍។ យើងបានសិក្សាអំពីកិច្ចខិតខំប្រឹងប្រែងរបស់វិស័យឯកជនកម្ពុជា ក្នុងការដោះស្រាយបញ្ហានេះ។ ការស្ទង់មតិរបស់យើងបានរកឃើញថា ក្រុមហ៊ុន ១ ភាគ ៣ ពុំចាត់វិធានការទេ ពេលជួបប្រទះទង្វើពុករលួយ និងខុសក្រមសីលធម៌ ក្នុងបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិ។ ក្រុមហ៊ុនក្នុងការស្ទង់មតិចំនួន ៥៨ ភាគរយ មិនដែលបដិសេធថា មិនបានបង់សំណូកនោះទេ ហើយក្រុមហ៊ុន ៧០ ភាគរយ ដែលបានបដិសេធមិនបង់សំណូកនោះ បានរាយការណ៍អំពីការយឺតយ៉ាវក្នុងការផ្តល់សេវាកម្ម ឬការមិនទទួលបានសេវាកម្មទាល់តែសោះ។ ការរៀបចំក្រមប្រតិបត្តិ និងគោលនយោបាយក្រុមហ៊ុនជាក់លាក់ ដើម្បីដឹកនាំបុគ្គលិកក្នុងស្ថានការណ៍មិនច្បាស់លាស់នេះ គឺជាបញ្ហាប្រឈម ជាពិសេសចំពោះសហគ្រាសធំៗ និងសមាជិក CAMFEBA។ ខណៈសហគ្រាសក្នុងការស្ទង់មតិចំនួន តែ ១៩ ភាគរយប៉ុណ្ណោះ មានគោលនយោបាយប្រភេទនេះ សមាជិក CAMFEBA ចំនួន ៦៤ ភាគរយមានគោលនយោបាយប្រភេទនេះ។

| សកម្មភាពរបស់វិស័យឯកជនក្នុងការកាត់បន្ថយផលប៉ះពាល់នៃអំពើពុករលួយ និងខុសក្រមសីលធម៌ | |
|---|---|
| **សកម្មភាព** | **ប្រេវ៉ាឡង់** |
| **បង្កើតក្រមប្រតិបត្តិ ឬគោលនយោបាយក្រុមហ៊ុនជាក់លាក់** | ១៩% |
| **បណ្តុះបណ្តាល/ដឹកនាំកម្មករនិយោជិតដែលអាចធ្វើទំនាក់ទំនងជាមួយនឹងមន្ត្រីពុករលួយ** | ១៦% |
| **កត់ត្រាឲ្យបានលំអិតអំពីទឹកប្រាក់ដែលបានបង់ និងពេលវេលាបង់** | ៨% |
| **ផ្សព្វផ្សាយយ៉ាងសកម្មនូវគោលនយោបាយមិនបង់ "កម្រៃក្រៅផ្លូវការបន្ថែម"** | ៥% |
| **ពុំបានធ្វើសកម្មភាពអ្វីទេ** | ៣៣% |
| **ត្រូវការជំនួយ/ មិនច្បាស់ថាតើត្រូវធ្វើអ្វី** | ១០% |
| **ផ្សេងទៀត** | ១៧% |

ប្រភព៖ ការស្ទង់មតិថ្នាក់ជាតិរបស់ CAMFEBA

[17] Global Integrity. របាយការណ៍ភាពសុចរិតសកលលោកឆ្នាំ ២០០៨.

ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជាក៏បានធ្វើសកម្មភាពរួមផងដែរ។ ក្នុងឆ្នាំ ២០១៣ CAMFEBA បានចាប់ផ្តើមដាក់ឲ្យអនុវត្តនូវក្របខណ្ឌរាយការណ៍ ដើម្បីប្រមូល វិភាគ និងបញ្ជូនទិន្នន័យស៊ីសំណូក ក្នុងគោលបំណងជួយអង្គភាពប្រឆាំងអំពើពុករលួយ។ តាមរយៈការរៀបចំ និងប្រមូលព័ត៌មាននេះដោយសំងាត់ CAMFEBA អាចផ្តល់ទិន្នន័យច្បាស់លាស់ និងសំណើជូនរដ្ឋាភិបាលដើម្បីដោះស្រាយកាត់បន្ថយអំពើពុករលួយ។ វិធីសាស្ត្រមានរចនាសម្ព័ន្ធ និងរក្សាការសំងាត់នេះបានអនុញ្ញាតឲ្យ CAMFEBA ធ្វើការវិភាគលំនាំបែបបទ ហើយលើកសំណើច្បាស់លាស់ជូនរដ្ឋាភិបាលដើម្បីធ្វើការកែលំអរ។

## អនុសាសន៍សម្រាប់គោលនយោបាយ

ស្ថិរភាព និងភាពអាចព្យាករណ៍បាន ដែលនាំមកដោយអភិបាលកិច្ចកាន់តែល្អប្រសើរ នឹងមានអត្ថប្រយោជន៍ទូលំទូលាយ ចំពោះសេដ្ឋកិច្ចរបស់យើង។ លទ្ធភាពទទួលបានឱកាស និងកិច្ចការពារពីរដ្ឋាភិបាលដោយស្មើភាពគ្នា និងមានប្រសិទ្ធិភាពថែមទៀត នឹងលើកកម្ពស់សមត្ថភាពធ្វើពាណិជ្ជកម្ម និងមុខមាត់ប្រទេសរបស់យើងជាទិសដៅវិនិយោគ។ ការអភិវឌ្ឍប្រទេសកម្ពុជានឹងត្រូវបានពន្លឿន តាមរយៈប្រព័ន្ធអភិបាលកិច្ចអេឡិចត្រូនិក នីតិវិធីមានតម្លាភាព និងការផ្តល់កិច្ចការពារផ្លូវច្បាប់ចំពោះជនទាំងឡាយដែលរាយការណ៍ពីអំពើខុសក្រមសីលធម៌។

១. **ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើពុករលួយ ដើម្បីធ្វើឲ្យច្បាប់កាន់តែមានប្រសិទ្ធិភាព**

- តម្រូវការជាបន្ទាន់គឺការលើកកម្ពស់ការយល់ដឹងថ្នាក់ជាតិអំពីច្បាប់នេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយទូទាំងខេត្តក្រុង។ ត្រូវផ្សព្វផ្សាយព័ត៌មានតាមរបៀបដែលងាយស្រួលយល់។
- អង្គភាពត្រួតពិនិត្យ ឃ្លាំមើលការអនុវត្តច្បាប់ គួរផ្សព្វផ្សាយព័ត៌មានឲ្យមានតម្លាភាព ដើម្បីឲ្យសាធារណជនទទួលបានព័ត៌មានថ្មី អំពីថាតើ អ្វីខ្លះដែលបានកើតឡើង និងថាតើដំណើរការទៅមុខយ៉ាងដូចម្តេច។
- គួរមានលក្ខណៈកាន់តែងាយស្រួលដើម្បីដាក់បណ្តឹងផ្លូវច្បាប់ ជាពិសេស ចំពោះសហគ្រាសធុនតូច និងមធ្យម (ឧទាហរណ៍ ប្រអប់ពាក្យបណ្តឹងអាចដាក់បង្ហាញជាសាធារណៈនៅទូទាំងប្រទេស)។ គួរអាចដាក់ពាក្យបណ្តឹងជាសំងាត់ផ្ទាល់ ហើយគួរមានកិច្ចការពារខ្លះៗចំពោះបុគ្គល ឬក្រុមណាមួយដែលធ្វើសកម្មភាពដើម្បីរាយការណ៍នូវអំពើល្មើស។
- ត្រូវការគោលការណ៍ណែនាំ និងជំនួយច្បាស់លាស់ ដើម្បីជួយក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនចាប់ផ្តើមដាក់ពាក្យបណ្តឹង។ គោលការណ៍ណែនាំទាំងនេះគួរមានគោលបំណងពន្យល់អំពីលក្ខខណ្ឌច្បាស់លាស់ ថាតើអ្វីខ្លះអ្នកប្តឹងត្រូវបំពេញ ដើម្បីធ្វើឲ្យពាក្យបណ្តឹងជាបណ្តឹងស្របច្បាប់ ថាតើភស្តុតាងអ្វីខ្លះដែលត្រូវការ និងថាតើជំហានអ្វីខ្លះគួរអនុវត្តដើម្បីធ្វើឲ្យពាក្យបណ្តឹងជាបណ្តឹងស្របច្បាប់។
- ច្បាប់បច្ចុប្បន្នមានចន្លោះប្រហោង (ឧទាហរណ៍ គ្មានកិច្ចការពារចំពោះអ្នករាយការណ៍ទេ)។ ចន្លោះប្រហោងទាំងនេះគួរកំណត់ឲ្យឃើញ ហើយត្រូវអនុវត្តផែនការ ដើម្បីកែតម្រូវស្ថានការណ៍នេះ ក្នុងគោលបំណងធ្វើឲ្យច្បាប់កាន់តែមានប្រសិទ្ធិភាពថែមទៀត។
- ក្រសួងទាំងអស់គួរផ្សព្វផ្សាយកម្រៃសេវាសាធារណៈរបស់ខ្លួនភ្លាមៗឲ្យកាន់តែទូលំទូលាយ។

**២. ជំរុញប្រសិទ្ធិភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

- អង្គភាពប្រឆាំងអំពើពុករលួយត្រូវទទួលយកភាគីពាក់ព័ន្ធបន្ថែមទៀត ដើម្បីឲ្យមានភាពជាតំណាងថែមទៀត។ ការទទួលយកនេះអាចបញ្ចូលទៅក្នុងក្រុមប្រឹក្សាភិបាល ឬបង្កើតក្រុមប្រឹក្សាផ្តល់យោបល់បន្ថែម។
- អង្គភាពប្រឆាំងអំពើពុករលួយត្រូវចូលរួមឲ្យកាន់តែជិតស្និតថែមទៀតជាមួយនឹងវិស័យឯកជន។

**៣. ប្រព័ន្ធតុលាការ**

- CAMFEBA ស្នើអង្គភាពប្រឆាំងអំពើពុករលួយធ្វើការត្រួតពិនិត្យលើប្រព័ន្ធតុលាការ។ ការត្រួតពិនិត្យគួរកំណត់រកបញ្ហា និងលើកជាអនុសាសន៍ដើម្បីធ្វើការកែលំអរ។ ការត្រួតពិនិត្យនេះគួរបញ្ចប់ក្នុងរយៈពេលជាក់លាក់ ដែលតាមអនុសាសន៍របស់យើង គួរមានរយៈពេល ១២ ខែ។
- ចៅក្រមគួរទទួលបានការបណ្តុះបណ្តាលបន្ថែម និងវគ្គបំប៉ន។
- គួរដាក់ឲ្យអនុវត្តនូវយន្តការ ដើម្បីវាយតម្លៃសេចក្តីសម្រេច ក្នុងគោលបំណងលុបបំបាត់អំពើពុករលួយ។

**៤. ការធ្វើលទ្ធកម្ម**

- ត្រួតពិនិត្យឡើងវិញលើវិធានដេញថ្លៃជាសាធារណៈ ដើម្បីធានាថា ការដេញថ្លៃប្រព្រឹត្តទៅដោយយុត្តិធម៌ និងមានតម្លាភាព។ គោលបំណងគឺធ្វើយ៉ាងណាឲ្យរាល់ការដេញថ្លៃជាសាធារណៈទាំងអស់គួរសម្រេចបាននូវតម្លៃល្អប្រសើរបំផុតសម្រាប់ការចំណាយសាធារណៈ។ គួរវាយតម្លៃលើការដេញថ្លៃចំពោះលទ្ធកម្មសាធារណៈធំៗទាំងអស់។
- នីតិវិធីលទ្ធកម្មសាធារណៈនៅកម្ពុជាគួរកំណត់ធៀបនឹងទម្លាប់អនុវត្តអន្តរជាតិដែលល្អប្រសើរបំផុត។

**៥. ការអប់រំ**

- គួរត្រួតពិនិត្យឡើងវិញលើដំណើរការប្រឡងថ្នាក់ជាតិទាំងអស់ ដើម្បីធានាភាពសុចរិតនៃលទ្ធផលប្រឡង។
- អ្នកអប់រំត្រូវទទួលការបណ្តុះបណ្តាលស្តីពីភាពសុចរិតនៃដំណើរការប្រឡង។
- CAMFEBA សូមស្នើឲ្យរៀបចំ និងដាក់បញ្ចូលកម្មវិធីក្រមសីលធម៌ពាណិជ្ជកម្ម ទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា។

# CAMFEBA – អនុវត្តតួនាទីរបស់យើង

**CAMFEBA នឹងបន្តធ្វើការជាមួយសមាជិក ដើម្បីកំណត់ជំនាញថ្មី និងបន្ទាន់ ដែលសេដ្ឋកិច្ចរបស់យើងត្រូវការ។**

- ✓ យើងនឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាល និងគ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីរៀបចំយុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម ដែលនឹងតម្រង់គោលនយោបាយអប់រំ និងបណ្តុះបណ្តាល ព្រមទាំងការផ្តល់សេវាកម្មឲ្យស្របទៅនិងសេចក្តីត្រូវការរបស់ពាណិជ្ជកម្មនៅកម្ពុជា។
- ✓ ដោយទទួលស្គាល់ក្តីកង្វល់ជាពិសេសរបស់និយោជកទាក់ទងនិងកម្រិតផលិតភាព CAMFEBA នឹងគាំពារសមាជិក ដោយមានគំនិតផ្តួចផ្តើមជួយពួកគេក្នុងការកំណត់រកវិធីសាស្ត្រដើម្បីសម្រេចនូវប្រសិទ្ធិភាពកាន់តែប្រសើរថែមទៀត។

**ដើម្បីជួយលើកកម្ពស់ទំនាក់ទំនងនៅកន្លែងធ្វើការនៅកម្ពុជា CAMFEBA នឹងចាត់វិធានការដូចខាងក្រោម៖**

- ✓ ផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ការងារ និងច្បាប់សហជីពថ្មី ក្នុងចំណោមក្រុមហ៊ុនពាណិជ្ជកម្ម ក្នុងគោលបំណងលើកកម្ពស់ការគោរពតាមច្បាប់។
- ✓ លើកទឹកចិត្តក្រុមហ៊ុនពាណិជ្ជកម្មឲ្យទាក់ទងកម្មករនិយោជិត ដើម្បីផ្តល់ព័ត៌មានដល់ពួកគេស្តីពីច្បាប់ការងារ និងថាតើច្បាប់ការងារអនុវត្តចំពោះពួកគេយ៉ាងដូចម្តេច។
- ✓ លើកទឹកចិត្តនិយោជកទាំងអស់ផ្តល់កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជូនកម្មករនិយោជិតជាប់លាប់ ដែលគួរចែងច្បាស់អំពីប្រការ និងលក្ខខណ្ឌការងារ និងគួរកំណត់នីតិវិធីអនុវត្តឲ្យបានច្បាស់លាស់ក្នុងក្រុមហ៊ុន ក្នុងករណីកើតមានបណ្តឹង។
- ✓ លើកទឹកចិត្តនិយោជក និងសហជីពឲ្យព្រមព្រៀងលើនីតិវិធី ដែលនឹងត្រូវអនុវត្ត ក្នុងករណីបណ្តឹងពុំត្រូវបានដោះស្រាយផ្ទៃក្នុងក្រុមហ៊ុន ដូច្នេះ អាចអនុវត្តវិធានការដែលកំណត់ដើម្បីស្វែងរកដំណោះស្រាយ ក្នុងរយៈពេលជាកំណត់ ហើយការរាំងស្ទះការងារ ឬកូដកម្មអាចជៀសវាងបាន។
- ✓ លើកទឹកចិត្តនិយោជកប្រើប្រាស់ឲ្យបានពេញលេញនូវយន្តការជំនួយ ដើម្បីជួយដោះស្រាយវិវាទ រាប់ទាំងការផ្សះផ្សារ និងមជ្ឈត្តកម្ម។

**យើងនឹងតំណាងសមាជិក ក្នុងទំនាក់ទំនងជាមួយនងរាជរដ្ឋាភិបាល ដើម្បីជួយបង្កើតបរិដ្ឋានមួយនៅកម្ពុជា ដែលជួយឲ្យក្រុមហ៊ុនពាណិជ្ជកម្មទទួលបានជោគជ័យ និងជួយឲ្យនិយោជកសម្រេចបាននូវឧត្តមភាពខាងពាណិជ្ជកម្ម**

- ✓ CAMFEBA នឹងធ្វើការធានាថា បទប្បញ្ញត្តិត្រូវបានរៀបចំឡើងនឹងត្រូវបានអនុវត្ត ដើម្បីឆ្លុះបញ្ចាំងនូវទម្លាប់អនុវត្តល្អ ហើយទន្ទឹមនឹងនេះ ជួយអភិវឌ្ឍពាណិជ្ជកម្ម និងលើកទឹកចិត្តដល់កំណើនសេដ្ឋកិច្ច។

យើងជឿជាក់យ៉ាងមុតមាំថា កំណែទម្រង់ច្បាប់ត្រូវអនុវត្តជាបន្ត ដើម្បីលុបបំបាត់ឧបសគ្គនៃការិយាល័យធិបតេយ្យ និងសម្រេចបាននូវលទ្ធផលដែលចង់បាន។

**CAMFEBA មានតួនាទីសំខាន់ក្នុងការបង្កើនការយល់ដឹងអំពីច្បាប់ប្រឆាំងអំពើពុករលួយ ហើយជួយលុបបំបាត់អំពើពុករលួយពីពាណិជ្ជកម្មកម្ពុជា។ ដើម្បីគាំទ្រសកម្មភាពនេះ យើងមានបំណងចាត់វិធានការ ដូចខាងក្រោម៖**

- ✓ ផ្តល់ជំនួយជាក់ស្តែងដល់ក្រុមហ៊ុន ដើម្បីជួយពួកគេរាយការណ៍អំពីអំពើពុករលួយ។
- ✓ លើកទឹកចិត្តក្រុមហ៊ុនឲ្យអនុម័តគោលនយោបាយរឹងមាំ ដែលគេយល់ដឹងជាទូទៅ និងដែលត្រូវគោរពតាមដោយកម្មករនិយោជិត តាមខ្លឹមសារ និងស្មារតីនៃច្បាប់ប្រឆាំងអំពើពុករលួយ។
- ✓ CAMFEBA នឹងបង្កើតវគ្គបណ្តុះបណ្តាល ដើម្បីជួយក្រុមហ៊ុនដោះស្រាយបញ្ហាស្នើសុំ ឬទាមទារកម្រៃសម្រួលការងារ។
- ✓ CAMFEBA នឹងចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ជាសាធារណៈ ហើយក៏នឹងពង្រឹងខ្លឹមសារនេះ តាមរយៈការបន្តផ្សព្វផ្សាយអំពីសារៈសំខាន់ នៅក្នុងទំនាក់ទំនងទាំងអស់ជាមួយនឹងរដ្ឋាភិបាល។ បន្ថែមពីលើនេះ CAMFEBA នឹងជូនដំណឹងសមាជិកជាប្រចាំអំពីការវិវត្តថ្មី តាមរយៈព្រឹត្តប័ត្រ និងគេហទំព័ររបស់យើង ហើយយើងនឹងលើកទឹកចិត្តសមាជិកយ៉ាងសកម្មឲ្យគោរពអនុវត្តតាមច្បាប់។